ក្រសួងអប់រំ យុវជន និង កីឡា

៤ សម្ភាសន៍ និងអង្កេត

បញ្ហាប៉ពលកម្មកុមារ

ការពារសិទ្ធិកុមារតាមរយៈការអប់រំ_សិល្បៈ និងប្រព័ន្ធផ្សព្វផ្សាយ

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

អង្គការពលកម្មអន្តរជាតិ

២០០៣



វត្ថុបំណង :

ធ្វើការអង្កេត និងសម្ភាសន៍អំពីពលកម្មកុមារក្នុងចំណោមបុគ្គលដែលពាក់ព័ន្ធ ។



លទ្ធផលរំពឹងទុក :

គាំទ្រដំណើរការបញ្ចូលរបស់សហគមន៍ និងធ្វើឱ្យមានការចាប់អារម្មណ៍ឱ្យកាន់តែទូលំទូលាយថែមទៀត។ ណែនាំបច្ចេកទេសសម្ភាសន៍ និងជំរុញការស្រាវជ្រាវនូវអ្វីដែលអ្នកដទៃទៀតកំពុងធ្វើ ស្តីអំពីពលកម្មកុមារនៅតំបន់ផ្សេងគ្នានៃសង្គម និងសេដ្ឋកិច្ច។

ការកំណត់ពេលវេលា

បង្រៀនពី៤ទៅ៦ដង

ហេតុផល

ចំណុចសំខាន់មួយដែលបានលើកឡើងជាច្រើនដងក្នុងម៉ូឌុលទាំងនេះគឺជា តម្រូវការសម្រាប់ជនគ្រប់រូបក្នុងសង្គមដើម្បីសម្រេចតួនាទីរបស់គេ និងម្ចាស់ការក្នុងយុទ្ធនាការលុបបំបាត់ពលកម្មកុមារ។ ការដែលប៉ាន់ស្មានថារដ្ឋាភិបាលខ្លះ ឬអង្គការសហប្រជាជាតិ នឹងយកចិត្តទុកដាក់ទៅលើបញ្ហានេះ គឺមិនគ្រប់គ្រាន់ទេ។ សហគមន៍អន្តរជាតិ កំពុងចាប់អារម្មណ៍ខ្លាំងទៀតនូវអ្វីដែលកើតឡើង សូម្បីនៅទីឆ្ងាយជាងគេក្នុងពិភពលោកនាពេលបច្ចុប្បន្ននេះក៏ដោយ។ ការស្តារឱ្យមានសន្តិភាពឡើងវិញ ដើម្បីលុបបំបាត់ទំនាស់នៃប្រទេសទាំងឡាយ និងសង្គ្រោះជនរងគ្រោះពីគ្រោះធម្មជាតិ ត្រូវបានអន្តរជាតិលើកជាបញ្ហាមួយដ៏ធំក្នុងកិច្ចប្រឹងប្រែងបច្ចុប្បន្ននេះ។

កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

វាប្រើប្រាស់ជាគំនិតដ៏ល្អមួយ សម្រាប់ប្រតិបត្តិភ្លាមៗបន្ទាប់ពីការស្រាវជ្រាវ និងផ្តល់ព័ត៌មានពីម៉ូឌុលនេះ។ លទ្ធផលនៃម៉ូឌុលនោះ នឹងផ្តល់វេទិកាសម្រាប់ណែនាំបច្ចេកទេសសម្ភាសន៍។

ម៉ូឌុលនេះក៏បានពង្រឹងដំណើរការស្រាវជ្រាវប្រហាក់ប្រហែលគ្នារួចមកហើយដែរ។

ម្យ៉ាងវិញទៀត មានកុមាររាប់លាននាក់កំពុងធ្វើការក្នុងពិភពលោក ដែលជោគវាសនារបស់ពួកគេមិនបានពឹងផ្អែកទៅលើដំណោះស្រាយនៃទំនាស់ប្រកបដោយសន្តិវិធីឡើយ។ ពួកគេមិនបានផ្សព្វផ្សាយជារឿងរាល់ថ្ងៃ។ គិតឱ្យសព្វគ្រប់ទៅ ក្មេងទុរគតជាច្រើនមិនបានទទួលចំណេះដឹង តាំងពីក្មេង និងពេលខ្លះគ្មានការអប់រំពីគ្រួសារ។ ពលកម្មកុមារមិនត្រឹមតែជារឿងមួយដែលអាចដោះស្រាយបានដោយសប្បុរសធម៌មួយមុខប៉ុណ្ណោះទេ។ ពេលខ្លះប្រជាពលរដ្ឋ ឬរដ្ឋាភិបាលពិតជាគិតថាការផ្តល់លុយនឹងអាចឱ្យពួកគេរួចខ្លួនពីការទទួលខុសត្រូវ។ វាមិនអាចប្រព្រឹត្តទៅបែបនោះឡើយ។ ទំនួលខុសត្រូវមួយដ៏ធំមិនមែនជាការងាយនឹងរំលងចោលបានឡើយ។

ដូច្នេះតើយើងនឹងធ្វើអ្វីហើយអ្វីដែលយើងសង្ឃឹមយ៉ាងមុតមាំដើម្បីសម្រេចគោលដៅ?តើយើងគិតថាតាមការបង្រួបបង្រួមយុវវ័យជុំវិញពិភពលោកពួកគេនឹងទទួលបានជោគជ័យឬ? តើយើងកំពុងតែដាក់អម្រែករួមរបស់យើងឱ្យពួកគេទទួលខុសត្រូវឬ? ទេមិនប្រាកដទេ។ ប៉ុន្តែមិនអាចធ្វើការជាមួយពួកគេដើម្បីយកកម្លាំងថាមពលភាពច្នៃប្រឌិត និងការប្តេជ្ញារបស់ពួកគេជាប្រយោជន៍ដើម្បីជួយបង្កើតធនធានដ៏ធំធេងរបស់អ្នកអប់រំសហគមន៍ដែលជាភ្នាក់ងារសង្កេតសម្រាប់ការបង្រួបបង្រួម និងបំលាស់ប្តូរនៃសង្គម។ ជាកង្វល់សហគមន៍ដែលបាននិយាយច្រំដែលៗ : យុវវ័យគឺជាសរសរទ្រូងសម្រាប់បច្ចុប្បន្ន និងអនាគតនៃ សហគមន៍របស់យើង ។

ប៉ុន្តែសហគន៍មិនមែនគ្រាន់តែកើតឡើងពីយុវវ័យប៉ុណ្ណោះទេ ។ សហគមន៍ត្រូវរាប់បញ្ចូលអ្នកនយោបាយ កម្មករ ឪពុកម្តាយ គ្រូបង្រៀន អ្នកសហជីពពាណិជ្ជកម្ម និយោជិត អាជីវករ កីឡាករ អត្តពលករ សិល្បករ សិល្បការិនីនៅក្នុងសង្គមទាំងមូល។ តើពួកគេកំពុងជួយអ្វី? ជាការពិតតើពួកគេយល់ដឹងអំពីបញ្ហាឬទេ? តើពួកគេដឹងថាពួកគេអាចនឹងគួរធ្វើអ្វីមួយដើម្បីផ្លាស់ប្តូរបញ្ហាឬទេ?

ម៉ូឌុលនេះបានបម្រើគោលបំណងមួយចំនួននៅក្នុងដំណើរការគរុកោសល្យ។ ក្លេងៗនៅក្នុងក្រុមរបស់អ្នកនឹងឆ្ងល់ពីអ្វីជាគោលដៅក្នុងការផ្តល់ព័តិមានក្នុងម៉ូឌុលមុនៗ។ តើអ្វីដែលត្រូវគេប៉ាន់ស្មានដើម្បីធ្វើជាមួយនឹងព័តិមានទាំងអស់នេះ? ជាមួយនឹងម៉ូឌុលនេះពួកគេនឹងមានឱកាសសំខាន់មួយ ដើម្បីផ្តល់ចំណេះដឹងរបស់ពួកគេដើម្បីការស្រាវជ្រាវពីបំណិន និងព័តិមានដើម្បីប្រើប្រាស់។ ដោយការដឹកនាំការសម្ភាសន៍ជាមួយនឹងគន្លឹះនៃការជំនួសមុខសហគមន៍របស់ពួកគេ ក្រុមអ្នកនឹងអភិវឌ្ឍសង្គម និងបំណិននៃការទាក់ទងដែលបម្រើពួកគេឱ្យល្អក្នុងការរស់នៅផ្ទាល់ខ្លួន និងការអប់រំរបស់ពួកគេ។ ពួកគេនឹងស្វែងរកអ្វីដែលពួកគេបានដឹងផ្សេងទៀតអំពីពលកម្មកុមារ តើពួកគេកំពុងព្យាយាមធ្វើបញ្ហាទាំងនេះ និងរបៀបដែលត្រូវធ្វើ ហើយថែមទាំងអ្វីដែលបុគ្គលម្នាក់ៗនៅក្នុងសង្គមអាចធ្វើស្តីអំពីពលកម្មកុមារផងដែរ។

អ្នកខ្លះទៀត ដូចជាអ្នក នយោបាយ អ្នកដឹកនាំជំនួញអាចដើរតួសំខាន់ក្នុងការជួយធ្វើយុទ្ធនាការដើម្បីលុបបំបាត់ពលកម្មកុមារ។ ប៉ុន្តែតើពួកគេកំពុងធ្វើអ្វីពិតប្រាកដមែនឬ?នេះគឺជាអ្វីដែលយើងចង់ឱ្យក្លេងសិក្សាស្វែងយល់។

នៅពេលដដែលនេះ ដោយចេញទៅធ្វើការសម្ភាសន៍ក្នុងសហគមន៍ យុវវ័យនឹងបង្កើនតួនាទីរបស់គេជាអ្នកអប់រំសហគមន៍។ បុគ្គលម្នាក់ៗដែលពួកគេសម្ភាសន៍ និងចង់ដឹងហេតុអ្វីបានជាពួកគេសួរអំពីពលកម្មកុមារ។ ពួកគេនឹងចង់ដឹងច្រើនថែមទៀតអំពីគម្រោង និងដំណើរការគរុកោសល្យ។ ពួកគេនឹងចង់ដឹងនូវអ្វីដែលអ្នកសម្ភាសន៍វ័យក្មេងទាំងនេះ។ ការពិតទៅ បុគ្គលខ្លះអាចមានអារម្មណ៍មិនល្អនៅក្នុងការសម្ភាសន៍ប្រភេទនេះ ហើយប្រហែលជាអាចបដិសេធមិនធ្វើសម្ភាសន៍។ការសម្ភាសន៍នេះគឺមានការសិក្សាជំហានដ៏ធំសម្រាប់ក្រុមរបស់អ្នកដូច ជាគេចមិនផុតពីការសួរថាតើហេតុអ្វីបានជាការសុំសម្ភាសន៍របស់ពួកគេត្រូវបានបដិសេធ និងអ្នកត្រូវតែឆ្លើយតបគេ ពោរពេញដោយភាពស្មោះ។

ក្រៅពីការកែលំអស្ថាបនា ការដឹកនាំសម្ភាសន៍ជំពូកនេះថែមទាំងសម្លឹងមើលបច្ចេកទេសស្ទាបស្ទង់មតិទាំងឡាយ និងបង្កើនដំណើរការស្រាវជ្រាវ ថែមទាំងជួយក្មេងៗក្នុងការរកឃើញបេក្ខជនសម្ភាសន៍ និងប្រភេទសំណួរដែលគេត្រូវសួរ។ តាមការពិតការស្រាវជ្រាវគឺ ជាគន្លឹះសកម្មភាពយ៉ាងសំខាន់នៅក្នុង IPEC ហើយវាដូចគ្នានឹងការប្រមូលព័ត៌មានពីក្រុមផ្សេងៗជុំវិញពិភពលោកនឹងអាចប្រើបានចំពោះ IPEC ក្នុងសកម្មភាពរបស់ខ្លួនផ្ទាល់។

ការរៀបចំ

យើងសំគាល់ដឹងថាកម្រិតនៃការអនុវត្តន៍វម៉ូឌុលនេះនឹងមានភាពខុសប្លែកគ្នាគួរពិចារណាពីក្រុមមួយទៅក្រុមមួយ ពីប្រទេសមួយទៅប្រទេសមួយ ដោយផ្អែកលើតរិយាបទ អាកប្បកិរិយា វប្បធម៌ និងទំនៀមទម្លាប់ជាទូទៅ។ វាសម្រេចទៅលើលោកអ្នកក្នុងការវាស់កម្រិតថាតើម៉ូឌុលនេះអាចត្រូវបានប្រតិបត្តិក្នុងការកំនត់របស់អ្នកឬទេ តើភាពប៉ះទង្គិចអាចជាអ្វី ដឹងថាតើដំណើរការគរុកោសល្យប្រហែលជាខាតបង់ដោយការប្រតិបត្តិរបស់ខ្លួនដែរឬទេ។ អាទិភាពទី១របស់អ្នកប្រាកដជាសុវត្ថិភាព និងសុខមាលភាពរបស់យុវវ័យនៅក្នុងក្រុមរបស់អ្នក និងការអប់រំរបស់ពួកគេ។ ចូរកុំយកផ្នែកខ្លះៗ នៅក្នុងម៉ូឌុលនេះមកអនុវត្ត ប្រសិនបើផ្នែកទាំងនោះអាចបង្កគ្រោះថ្នាក់ដល់ក្រុមទោះ តាមរបៀបណាក៏ដោយ។



ជំនួយពីខាងក្រៅ

ក្នុងម៉ូឌុលនេះគឺងាយស្រួល ហើយអ្នកមិនចាំបាច់ត្រូវការជំនួយផ្សេងទៀតនៅក្នុងការប្រតិបត្តិវាទេ។ ទោះជាយ៉ាងណាក៏ដោយ ការទ្រាំទ្រដែលផ្តល់ឱ្យក្នុងការបង្រៀន និងដំណើរការប្រមូលផ្តុំពត៌មានជានិច្ចកាលគួរតែទទួលដោយភាពកត្តញ្ញូ ប្រសិនបើអ្នកមានជោគវាសនាគ្រប់គ្រាន់ ដើម្បីទទួលការគាំទ្រពីបណ្ណាល័យមូលដ្ឋានទាំងឡាយក្នុងការស្រាវជ្រាវ និងម៉ូឌុលព័ត៌មាននោះប្រហែលជាគេសុខចិត្តផ្តល់សេវាកម្មរបស់ពួកគេម្តងទៀតសម្រាប់ម៉ូឌុលនេះ។ ការត្រៀមរៀបចំសម្រាប់សម្ភាសន៍ និងការស្ទាប់ស្ទង់មតិទាំងឡាយនឹងត្រូវការស្រាវជ្រាវក្នុងផ្នែកនៃក្រុម ។

លើសពីនេះទៅទៀត ប្រសិនបើអ្នកកំពុងធ្វើការងារក្នុងផ្នែកអប់រំក្នុងប្រព័ន្ធនោះ វាអាចថាអ្នកប្រហែលជារកបានគ្រូមុខវិជ្ជាគណិត និងស្ថិតិ។ ការពិតថ្វីបើអ្នកកំពុងធ្វើការក្នុងផ្នែកអប់រំក្រៅប្រព័ន្ធ អ្នកប្រហែលជានៅស្គាល់គ្រូមុខវិជ្ជាទាំងនេះ ។ ជំនាញ និងជំនួយរបស់ពួកគេអាចបង្ហាញពីសារៈប្រយោជន៍ក្នុងការអភិវឌ្ឍ និងការដឹកនាំស្ទាបស្ទង់មតិ និងការវិភាគស្ថិតិរបស់ពួកគេ។

ទន្ទឹមនឹងនេះ ប្រសិនបើអ្នកស្គាល់បុគ្គលណាម្នាក់ដែលមានបទពិសោធន៍ខាងបច្ចេកទេសសម្ភាសន៍ដូចជាអ្នកកាសែត ឬអ្នកណាម្នាក់ធ្វើការក្នុងប្រព័ន្ធផ្សព្វផ្សាយ និងប្រព័ន្ធព័ត៌មាន មនុស្សបែបនោះ ជាមនុស្សម្នាក់អាចជួយយកអាសាគ្នាក្នុងការប្រតិបត្តិម៉ូឌុលនេះ។ ចូរទាក់ទងគេ និងពន្យល់ពីប្រភេទគម្រោងរបស់អ្នក និងម៉ូឌុលពិសេសនេះ អ្នកគ្មានបាត់បង់អ្វីទេ ប្រសិនបើមនុស្សនោះសុខចិត្តមក និងផ្តែងទៅកាន់ក្រុមស្តីពីបច្ចេកទេសសម្ភាសន៍ ឬមួយគាំទ្រក្រុមក្នុងការរៀបចំត្រៀមខ្លួនធ្វើសម្ភាសន៍នោះ លទ្ធផលរបស់ម៉ូឌុលនេះនឹងត្រូវបានកែលម្អប្រកបដោយភាពសំខាន់ ។

ចូរកុំគិតពីតម្រូវការចង់បានជំនួយពីខាងក្រៅថាជារឿងសំខាន់ ប៉ុន្តែតាមសញ្ញាដដែលនេះចូរកុំព្រងើយកន្តើយពីសក្តានុពលរបស់វា។ ម៉ូឌុលទាំងនេះគ្មានបំណងទម្លាក់បន្ទុកលើអ្នកអប់រំទេ។ គោលបំណងគឺមិនគ្រាន់តែបណ្តុះបណ្តាលជំនាញវិភាគស្ថិតិ ឬមួយក៏ឧបករណ៍សម្ភាស ប៉ុន្តែយុវវ័យនឹងទទួលបានប្រយោជន៍ច្រើនពីការណែនាំវិធីសាស្ត្រ និងពីការបង្កើនជំនាញថ្មីៗ។ ផ្អែកលើមូលដ្ឋានព័ត៌មានដែលបានផ្តល់រួច ហើយនៅក្នុងម៉ូឌុលទាំងនេះ អ្នកគួរតែអនុវត្តសកម្មភាពទាំងនេះដោយផ្ទាល់។ ទោះជាយ៉ាងណាក៏ដោយ ផ្នែករបស់ដំណើរការអប់រំសហគមន៍គឺមានប្រយោជន៍ ដើម្បីទៅជិតអ្នកផ្សេងទៀតឱ្យឃើញថាតើពួកគេអាចជួយការងារនៅក្នុងគម្រោងនេះដែរឬទេ ហើយតាមរបៀបណា? មនុស្សជាច្រើនបានចាប់អារម្មណ៍ពីគម្រោងនេះហើយល្មមនឹងសប្បាយរីករាយក្នុងការឱ្យខ្ចីសេវាកម្មដោយឥតគិតថ្លៃដើម្បីជួយជ្រោមជ្រែងដល់បុព្វ ហេតុប្រកបដោយភាពវិជ្ជមាន និងត្រឹមត្រូវ ។

អ្វីដែលអ្នកត្រូវការ



- ✓ ក្រដាស និងបិច ឬក៏ខ្មៅដៃ
- ✓ ក្តារខៀនពណិខ្មៅ ពណិស ឬផ្ទាំងផ្ដត់រូបភាពដែលអាចបត់បាន
- ✓ ធនធានសម្ភារឧបទេសស្តីពីពលកម្មកុមារ (មើលពត៌មានសំខាន់ ការស្រាវជ្រាវ និងពត៌មានក្នុងជំពូកទាំងនេះ)។
- ✓ ប្រើប្រាស់អ៊ីនធើណែតប្រសិនបើអាចមាន
- ✓ សរសេរតារាងស្តីពីនយោបាយជំនួញ អង្គការ និងតំណាងសហគមន៍ផ្សេងៗដែលជាអ្នកសម្ភាសន៍។
- ✓ ថតវីដេអូប្រសិនបើអាចមាន

ការចាប់ផ្តើម

ការរៀបចំក្រុមអាស្រ័យទៅលើទំហំ និងការស្វិតស្វាញក្នុងក្រុមទាំងមូល និងការបិនប្រសប់ខាងស្ម័យរៀបចំសកម្មភាព និងការសន្យារបស់អ្នក ។ ម៉ូឌុលនេះគឺទាក់ទងនឹងការស្វែងយល់អំពីព័ត៌មានការវិភាគ និងការសម្ភាសន៍ក្រុមទី៣ ការសម្ភាសន៍ទាំងក្នុងការប្រតិបត្តិ ទាំងក្នុងការរៀបចំរបស់គេគឺធ្វើបានល្អនៅក្នុងក្រុមតូចៗដែលមាន២ ប ្ ៣ នាក់ ទោះជាយ៉ាងណាក៏ដោយ ក៏ការសម្ភាសន៍នេះអាស្រ័យទៅលើវិសាលភាពនៃការសម្ភាសន៍។ ក្នុងក្រុមអាចរៀបចំការស្ទាប់ស្តង់មតិ ឬមួយប្រសិនបើអ្នកកំពុងធ្វើគម្រោងដើម្បីដឹកនាំការ ស្ទាបស្តង់មតិច្រើនជាងម្នាក់ អ្នកអាចចែកក្រុមតូចៗ។

នៅពេលពួកគេត្រៀមខ្លួនសម្រាប់សម្ភាសន៍ យុវជនធ្វើការក្រុមតូចៗល្អជាងធ្វើម្នាក់ឯងដូចជាសំណួរនៃការជឿជាក់ និង "មានសុវត្ថិភាពច្រើន " ។ វាអាចធ្វើឱ្យអស់ទំនុកចិត្តនៃក្តីសង្ឃឹមរបស់ក្មេងម្នាក់ក្នុងការស្រាវជ្រាវ និងដឹកនាំសម្ភាសន៍ម្នាក់ឯង។ តាមបទពិសោធន៍ សុំឱ្យយ៉ាងតិចមានពីរ យ៉ាងច្រើនឱ្យមានបីសម្រាប់សម្ភាសន៍មនុស្សម្នាក់។ ទោះជាយ៉ាងណាក៏ដោយប្រសិនបើមនុស្សបីបួននាក់ត្រូវសម្ភាសន៍ចំនួន អាចកើន ប៉ុន្តែមិនច្រើនពេកទេ។ត្រូវគិតថាអ្នកចង់ឱ្យបុគ្គលម្នាក់ៗចូលរួមក្នុងការអនុវត្ត ហើយមិនអាចលាក់ខ្លួនពីក្រោយការងារ និងការសន្យាផ្សេងទៀតឡើយ។



ចូរពិចារណាយ៉ាងប្រុងប្រយ័ត្នអំពីភាពស្មោហាប់របស់ក្រុមពេលដែលបង្កើតក្រុមតូចៗ។ ពួកគេត្រូវធ្វើការល្អរលួនជាមួយគ្នាក្នុងក្រុម ជាពិសេសក្នុងការស្រាវជ្រាវ។ វាមានសារៈសំខាន់ណាស់ដែលមនុស្សគ្រប់គ្នាមានទំនាក់ទំនងគ្នា។

សកម្មភាព ១ : ការអង្កេត

បង្រៀនពី២ទៅ៣ដងក្នុងពេលធ្វើអង្កេត

កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

ទោះបីជាធ្វើឬមិនធ្វើការស្ទាបស្ទង់មតិក៏ដោយគឺជាជម្រើសមួយ។ ដំណើរការគឺបង្ហាញនៅក្នុងម៉ូឌុលនេះ ប៉ុន្តែមិនជាសំខាន់ណាស់ណាទេ។ អ្នកប្រហែលជាសម្រេចចិត្តប្រតិបត្តិការស្ទាបស្ទង់មតិ ឬការសម្ភាសន៍ក៏បាន ឬ ទាំងពីរ ឬ គ្មានមួយណាសោះ ទោះជាយ៉ាងណាក៏ដោយយើងទទួលធ្វើយ៉ាងហោចឱ្យបានមួយក្នុងសកម្មភាពទាំងនេះនៅក្នុងក្រុម ឬ មួយក៏ធ្វើទាំងអស់ប្រសិនបើអាចធ្វើបាន។

ធម្មជាតិនៃការអង្កេត

តើមនុស្សប៉ុន្មាននាក់នៅក្រៅក្រុមនេះដឹងអំពីពលកម្មកុមារ?តើមានកុមារប៉ុន្មាននាក់ដែលគេយកចិត្តទុកដាក់? តើគេដឹងថា គ្រប់ៗគ្នាអាចដើរតួនាទីក្នុងប្រភេទយុទ្ធនាការលុបបំបាត់ពលកម្មកុមារដែរឬទេ? តើយុវជនក្នុងក្រុមរបស់អ្នកចាប់អារម្មណ៍កិរិតណា ក្នុងការស្វែងរកនូវអ្វីដែលអ្នកដទៃដឹងអំពីរឿងនេះ? តើពួកគេសប្បាយរីករាយចំពោះក្តីសង្ឃឹមនៃការដឹកនាំ ស្ទាបស្ទង់មតិ និងប្រាប់អ្នកដទៃទៀតអំពីអ្វីដែលកំពុងធ្វើដែរឬទេ? ការស្ទាបស្ទង់មតិមានសារៈប្រយោជន៍ណាស់នៅក្នុងដំណើរការលើកកម្ពស់ចំណេះដឹង។ ក្រុមរបស់អ្នកនឹងចងក្រងព័ត៌មានជាច្រើននាបច្ចុប្បន្ននេះ អំពីរឿងផ្សេងៗជុំវិញពលកម្មកុមារ។ វាមានសារៈសំខាន់ និងផ្តល់បទពិសោធន៍សម្រាប់ពួកគេ ដើម្បីអនុវត្តន៍ប្រើប្រាស់ជាក់ស្តែងនូវព័ត៌មានទាំងនោះ និងប្រាប់អ្នកផ្សេងទៀតឱ្យដឹងដោយប្រយោល នូវអ្វីដែលគេកំពុងធ្វើអំពីពលកម្មកុមារ ។

ចែកក្រុមនៅក្នុងបន្ទប់ធម្មតាឬក្នុងថ្នាក់រៀនរបស់អ្នក។ ឱ្យពួកគេអង្គុយតាមរបៀបក្នុងថ្នាក់រៀន ឬរាងជាអក្សរអ៊ុយជុំវិញអ្នកពួកគេមិនត្រូវការសម្ភារឧបទេសនៅក្នុងដំណាក់នេះទេ។ បង្ហាញមេរៀនលើចំនុចសំខាន់នៃកថាខណ្ឌខាងលើ និងពន្យល់ថាតើការអង្កេតស្ទាបស្ទង់នេះមានន័យដូចម្តេច? តើមានមូលហេតុអ្វីទើបត្រូវអនុវត្តការអង្កេតនេះក្នុងសង្គម និងអនុវត្តយ៉ាងដូចម្តេច?

តើអង្គភាពប្រភេទណាដែលត្រូវធ្វើការស្ទាបស្ទង់មតិនេះ? ឧទាហរណ៍ : ក្រុមហ៊ុនទីផ្សាររដ្ឋាភិបាល NGOs និងសហព័ន្ធពាណិជ្ជកម្ម ហើយគេយកលទ្ធផលទៅប្រើប្រាស់ដូចម្តេច ចូរពន្យល់ពីសារៈសំខាន់នៃការស្ទាបស្ទង់មតិចំពោះការប៉ាន់ស្មានឥរិយាបថ និងអាកប្បកិរិយា ហើយហេតុអ្វីបានជាមានសារៈសំខាន់ខ្លាំងចំពោះ យុទ្ធនាការលុបបំបាត់ពលកម្មកុមារ។

មានសំណួរមូលដ្ឋានច្រើនដែលត្រូវសួរក្នុងការសម្រេចចិត្តថា តើគួរធ្វើការស្ទាបស្ទង់មតិឬអត់ ហើយធ្វើដោយរបៀបណា។ មេរៀននេះគួរប្រើទម្រង់លំហាត់ប្រមូលផ្តុំគំនិតរួម ពេលដែលសួរទៅក្រុម ប្រសិនបើគេមានអារម្មណ៍ថាមានសារៈប្រយោជន៍នឹងធ្វើ ល្បែងស្ទង់មតិ។ នៅចុងបញ្ចប់មេរៀនគេគួរតែអភិវឌ្ឍបាននូវស្មារតីម្ចាស់ការសម្រាប់ការស្ទាបស្ទង់មតិ និងត្រៀមចេញទៅហើយចាប់ផ្តើមធ្វើការរៀបចំ។ ចាត់អ្នកណាម្នាក់ក្នុងក្រុមឱ្យឡើងធ្វើជាលេខា។ ពួកគេអាចតាមដានការពិភាក្សានៅលើក្តារខៀន ឬផ្ទាំងផ្ដត់រូបភាពអាចបត់បានឬធ្វើការកត់ត្រាពេលដែលអង្គុយនៅទីកន្លែងរបស់គេ។ បញ្ហាចម្បងដែលអ្នកគួរតែពិភាក្សាជាមួយក្រុមមានដូចតទៅ :

- ហេតុអ្វីបានជាយើងចង់ធ្វើការអង្កេត? តើមានគោលបំណង និងទិសដៅអ្វីខ្លះ ឧទាហរណ៍ : តើយើងកំពុងតែស្វែងរកព័ត៌មានឬ? ធ្វើការប៉ាន់ស្មានពីឥរិយាបថ សិក្សាពីអាកប្បកិរិយាសិក្សាពីដំណើរការជំនួញផ្សេងៗ ឬកំពុងសម្លឹងរកមើលអាទិភាព ។ ល ។ និង ។ល។
- តើអ្នកណាដែលជាមុខសញ្ញាក្នុងការស្ទាបស្ទង់មតិ? តើយើងចង់ផ្តោតធ្ងន់ទៅលើក្រុមសង្គមតែមួយឬច្រើនក្រុម? តើយើងធ្វើការស្ទាបស្ទង់មតិម្តងឬក៏ច្រើនដង? នេះអាស្រ័យទៅលើទំហំដ៏ធំរបស់គោលបំណង និងទិសដៅ។
- តើការអង្កេតនេះធ្វើឡើងក្នុងរូបភាពបែបណា? ទៅតាមរបៀបជាការបំពេញកម្រងសំណួររួចយកត្រឡប់មកវិញ? ឬក៏នៅក្នុងរូបភាពនៃការសម្ភាសន៍ម្តងមួយៗ? តើវាជាបញ្ហីសំនួរធ្វើតាមប្រៃសណីយ៍ឬ? (**រំលឹក** : ស្ទង់មតិតាមរយៈប្រៃសណីយ៍ត្រូវចំណាយលុយ និងចំណាយពេលច្រើន)។
- តើពេលណាដែលយើងចង់ធ្វើការអង្កេត? តើមានពេលពិសេសមួយ ឬពេលដែលល្អជាងនេះដើម្បីធ្វើការស្ទាបស្ទង់មតិឬទេ? ឧទាហរណ៍ ប្រសិនបើការអង្កេតត្រូវបានធ្វើឡើងក្នុងសាលាមួយ តើគេអាចធ្វើក្នុងកំឡុងពេលសិក្សា ឬ ក្នុងកំឡុងពេលសម្រាក ឬទេ?
- តើការស្ទាបស្ទង់មតិមានរយៈពេលប៉ុន្មាន និងមានភាពលំអិតដូចម្តេច?

វាប្រហែលជាអាស្រ័យទៅលើអ្នកស្តាប់ដែលជាមុខសញ្ញា និងរូបភាពនៃការស្ទាបស្ទង់មតិផងដែរ។ ទោះជាយ៉ាងណាក៏ដោយក្រុមរបស់អ្នកត្រូវចាប់អារម្មណ៍ថាចំពោះការស្ទាបស្ទង់មតិនោះគួរតែធ្វើឱ្យខ្ជិលល្មមព្រោះថា មនុស្សខ្លះមានការធុញទ្រាន់ចំពោះកម្រងសំណួរលំអិតវែងឆ្ងាយ។ ប្រសិនបើអ្នកធ្វើការសម្ភាសន៍ម្តងមួយៗ វាជានិច្ចកាលអាចប្រើសំណួរច្រើនប្រសិនបើមានអារម្មណ៍ថាកម្មវត្ថុនៃសំណួរត្រូវបានគេត្រៀមលក្ខណៈដើម្បីផ្តល់ជាចម្លើយ។

- តើការអង្កេតនេះមានកម្រិតពេលវេលាត្រឹមណា? ពេលណាដែលយើងគប្បីព្រោងថាប្រតិបត្តិវាជាវិភាគ និងបោះពុម្ពចេញជាលទ្ធផលអង្កេត?

  បញ្ហាផ្សេងទៀតនឹងលេចឡើងក្នុងកំឡុងពេលវគ្គប្រមូលគំនិតរបស់អ្នក ហើយអ្នកអាចកត់ត្រាទុកនូវបញ្ហាទាំងនេះផងដែរ។ អ្នកគួរតែរៀបចំឱ្យល្អសម្រាប់មេរៀននេះ ដូច្នេះអ្នកអាចបំពេញចន្លោះជាច្រើនដែលកើតមានឡើង ឬមួយថែរក្សាល្បឿនប្រសិនបើអាចមានពេល។ ម្យ៉ាងទៀតដើម្បីឱ្យគេចាប់អារម្មណ៍ខ្លាំងនិងចូលរួមគឺសុំឱ្យមានការស្ទាបស្ទង់មតិដែលត្រូវអនុវត្តគួរតែផ្តោតទៅលើក្រុមដែលមានសមត្ថភាពប្រហាក់ប្រហែលគ្នា។ វានឹងបង្ហាញពីការប្រលងប្រណាំងមួយដែលគួរឱ្យភ្ញាក់ផ្អើលចំពោះក្រុម និងផ្តល់នូវការកំសាន្តដ៏ច្រើនចំពោះក្តីសង្ឃឹមក្នុងការស្ទង់មតិរបស់មិត្តភក្តិនិងមនុស្សផ្សេងទៀតដែលមានអាយុស្មើៗគ្នា ។

  ហេតុផលមួយទៀតដែលជាយោបល់ល្អក្នុងការចាប់ផ្តើមអង្កេតមិត្តភក្តិ ដែលមានសមត្ថភាពស្រដៀងគ្នានោះគឺថាគម្រោងនេះទាក់ទិននឹងយុវវ័យ ហើយវិធីដែលធ្វើឱ្យពួកគេចូលរួមយុទ្ធនាការលុបបំបាត់ពលកម្មកុមារ ការស្ទង់មតិចំពោះយុវវ័យផ្សេងទៀតគឺចង់ដឹង ចង់ឃើញយ៉ាងខ្លាំងអំពីអ្វីដែលមិត្តរបស់ពួកគេនិងអ្នកដែលមានសមត្ថភាពប្រហែលពួកគេកំពុងធ្វើ និងទំហំសក្តានុពលនៃការផ្តល់ចំណេះដឹង។ នេះគឺពិតប្រាកដណាស់ ប្រសិនបើអ្នកកំពុងធ្វើការក្នុងបរិស្ថានសាលារៀនជាកន្លែងដែលសិស្សដទៃទៀតបានឮរួចហើយអំពីគម្រោងដែលអ្នកកំពុងដឹកនាំ។ លើសពីនេះទៅទៀតបរិស្ថានសាលារៀនមួយផ្តល់ឱ្យក្រុមស្ទាបស្ទង់មតិបានល្អ។

ការរៀបចំប្លង់អង្កេត

ម្តងនេះការពិភាក្សាចាប់ផ្តើមធ្វើសញ្ញាបញ្ឈប់វគ្គបំផុសគំនិតរួម ចូរសង្ខេបនូវចំនុចសំខាន់ៗដែលបានលើកឡើងកំឡុងពេលពិភាក្សា ជាមួយនឹងលេខាធិការសរសេរឡើងវិញឬមួយប្រាប់ឱ្យបុគ្គលម្នាក់ៗសរសេរមេរៀនទាំងនេះលើក្តារខៀន ឬក្តីបឆាត ដើម្បីងាយស្រួលមើលមេរៀនទាំងអស់នេះ។ សញ្ជឹងគិតដល់ចំណុចនីមួយៗនៃរាល់ចំណុច

ទាំងឡាយដែលបានលើកឡើង ហើយងាកមើលទៅខាងក្រោយវិញចំពោះក្រុមយើង ប្រសិនណាមានចំណុចជាច្រើនដែលលេចចេញ។ តើពួកគេយល់ព្រម ឬមិនយល់ព្រមជាមួយអ្វីដែលគេបានសរសេរ? ពេលមេរៀននេះបញ្ចប់លោកអ្នកស្ថិតនៅតំណាក់កាលដែលក្រុមបំបែកទៅជាក្រុមតូចៗឬរក្សាក្រុមធំដដែល ហើយការងារអាចចាប់ផ្តើមការរៀបចំ និងការអភិវឌ្ឍនៃការអង្កេត។ ដោយបានពិភាក្សាទៅលើចំណុចសំខាន់នីមួយៗខាងលើ ហើយបានសរសេរឡើងវិញនូវលទ្ធផលរបស់ការពិភាក្សានេះ ក្រុមមានព័ត៌មានទាំងអស់ និងសម្ភារដែលគេត្រូវការ រួចហើយដើម្បីបន្តការរៀបចំនៃការស្ទាបស្ទង់មតិ និងការព្រាងយ៉ាងពិតប្រាកដរបស់សំណួរទាំងអស់។ ប្រសិនបើអ្នកមានសំណាងគ្រប់គ្រាន់ ដើម្បីសុំឱ្យមានការគាំទ្រនៅក្នុងលំហាត់ អង្កេតនេះជាពេលវេលាដ៏ល្អបំផុតសម្រាប់ណែនាំមនុស្សនោះឱ្យជួយជំហានបន្តទៀតដែលជាបញ្ហាលំបាកបំផុតសម្រាប់ក្រុមរបស់អ្នក ។

ដោយគោរពទៅតាមពេលវេលា និងទម្រង់ដែលមានការយល់ព្រមពីសមាជិកក្រុមទាំងមូល អ្នកគួរបន្តការរៀបចំការអង្កេតនិងព្រាងសំណួរជាច្រើន។ ការងារនេះអាចធ្វើជាក្រុមទាំងមូលដែលដឹកនាំក្រុមដោយខ្លួនឯង ឬដោយធនធានមនុស្សពីខាងក្រៅ ឬក្នុងក្រុមតូចៗដែលអ្នក និងអ្នកខាងក្រៅធ្វើសកម្មភាពក្នុងចំណោមក្រុមតូចដោយផ្តល់ជំនួយ និងគាំទ្រពេលដែលគេត្រូវការដោយបានចែងថាការស្ទង់មតិមិនគួរវែងទេ អ្នកនឹងត្រូវសំរួលការងារក្រុម។ ព្យាយាមនិយាយទៅកាន់ក្រុមពេលដើរជុំវិញពួកគេលើកទឹកចិត្តពួកគេឱ្យគិតដោយប្រុងប្រយ័ត្នអំពីថា តើសំណួរធ្វើសម្រាប់អ្នកណា ហើយតើក្រុមចង់ស្វែងយល់អ្វី។ ពេលដំណើរការពង្រាងត្រូវបញ្ចប់ នាំក្រុមទាំងអស់ពិភាក្សាម្តងទៀតលើសំណើផ្សេងៗគ្នា។ គោលដៅនៃដំណើរការនេះគឺដើម្បីធ្វើឱ្យប្រសើរឡើងនូវការអង្កេតបញ្ជីសំណួរទាំងអស់គ្នាដូចនេះហើយទើបការអនុវត្តអាចចាប់ផ្តើមជាបន្តបន្ទាប់។ ក្នុងវគ្គនេះត្រូវមានភាពរស់រវើក ព្រោះថាក្រុមនីមួយៗត្រូវញាប់ដៃញាប់ជើងដើម្បីធ្វើពង្រាងរបៀបដឹកនាំមេរៀនគឺ អាស្រ័យលើរបៀបបំបែកក្រុម និងថាតើការងារផ្សេងៗទៀតគឺអ្វី។ ឧទាហរណ៍ : តើក្រុមផ្សេងៗគ្នាធ្វើកំរងសំណួរអង្កេតសម្រាប់ក្រុមមុខសញ្ញាខុសៗគ្នា ឬតើក្រុមនិមួយៗមានកិច្ចការដូចគ្នាឬ? កំរងសំណួរគឺប៉ាន់ប្រមាណឱ្យខ្លី ហើយ ច្បាស់ដំណើរការនេះមិនគួរឱ្យវែងពេកទេ ។

កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

លំហាត់ស្ទាបស្ទង់មតិម្យ៉ាងទៀតដែលអាចកើតឡើងគឺកម្រងសំណួរគំរូដែលអ្នកបញ្ចូលគ្នាជាក្រុមសម្រាប់ប្រើជាឯកសារយោង។ គេបានព្រាងដោយខ្លួនគេរួចហើយ។ ទោះបីជាដឹងតិចតួចក៏ដោយក៏ក្រុមបានគិត និងស្រមៃនូវពង្រាងសំណួរជាច្រើន ។

កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

សេចក្តីណែនាំច្បាស់លាស់គួរដាក់នៅខាងលើបញ្ជីសំណួរស្ទាបស្ទង់មតិសេចក្តីណែនាំទាំងនេះ គួរតែធ្វើសម្រាប់សម្គាសន៍ប្រសិនបើការអង្កេតមួយម្តងៗលើការសរសេរអក្សរ ឬគិត។ ដល់ការសរសេរ ប្រសិនបើការស្ទាបស្ទង់មតិផ្តោតទៅលើការសរសេរបញ្ជីសំណួរ។ សំខាន់គឺគួរតែឱ្យយល់ច្បាស់ពី របៀបប៉ាន់ស្មានដើម្បីជាការ ឆ្លើយតបរបស់ពួកគេ។ សំណួរមិនត្រូវស្រពិចស្រពិល ឬមិនច្បាស់លាស់នោះទេ។

ហើយកុំអូសបន្លាយឱ្យយូរទៀតព្រោះថាក្រុមនេះនឹងត្រូវកាត់បន្តរទៅរកដំណាក់ការបន្តទៀត។

អាស្រ័យទៅលើធនធានដែលអាចរកបាន ក្នុងការវាយអក្សរ និងការថតចម្លងនៅពេលកម្រងសំណួរស្ទង់មតិធ្វើ រួចហើយចាត់ម្នាក់ ក្នុងក្រុមវាយអក្សរឱ្យស្អាត បន្ទាប់មកថតចម្លងតាមសេចក្តីត្រូវការ ប្រសិនបើម៉ាស៊ីនកុំព្យូទ័រ ឬ ម៉ាស៊ីនថតចម្លងមិនអាចរកបាន។ ឱ្យអ្នកសរសេរអក្សរស្អាត ហើយច្បាស់សរសេរដោយផ្ទាល់ដៃរ។ ប្រសិនបើអ្នកមិនមានរបស់របរអាចរកបាន អ្នកនឹងដឹកនាំការស្ទាបស្ទង់មតិដោយផ្ទាល់មាត់ក៏មិនបានល្អដែរ។ ចាត់ក្រុមតូចៗឱ្យទទួលខុសត្រូវលើការធ្វើ និងចតចម្លងកម្រងសំណួរស្ទាបស្ទង់មតិ។ នៅពេលកិច្ចការបានបំពេញរួចហើយ ក្រុមបានឆ្លងទៅរកដំណាក់ការបន្តទៀត ។

ធ្វើការអង្កេត

កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

លក្ខណៈរបស់ការស្ទាបស្ទង់មតិ គឺត្រូវដើរតួក្នុងដំណើរការរៀបចំរបស់វានេះ ពិតជាពិសេសក្នុងការធ្វើសម្ភាសន៍ម្តងមួយៗ ប្រសិនបើអ្នកសម្ភាសន៍មិនមានសម្ភារៈ ប្រដាប់ថត វីដេអូ ឬក៏ខ្សែអាត់ថតសម្លេង ឬបំណិនខាងសរសេរកាត់ទេនោះ វាពិបាកធ្វើការកត់ត្រាការឆ្លើយតបរបស់ប្រជាជនជាអក្សរពេញ។

ដូច្នេះផ្នែកសំខាន់នៃលំហាត់មុនក្នុងការរៀបចំ ឬ ទំរង់នៃការស្ទង់មតិ ត្រូវបង្កើតក្រដាសសម្ភាសន៍ជាមួយសំណួរជ្រើសរើសជាច្រើនប្រសិនបើអាច គឺថាកន្លែងចម្លើយប្រហែលជាបាទ ចាស៎ ទេ ឬមិនដឹងទេ។ប្រសិនបើអ្នកសម្ភាសន៍គ្រាន់តែគូសសញ្ញាក្នុងប្រអប់ ☑ ឬសរសេរឃ្លាខ្លីៗលើក្រដាសសម្ភាសន៍នោះកិច្ចការនឹងងាយស្រួលជាងមុនហើយដំណើរការវិភាគបន្តបន្ទាប់ក៏យ៉ាងដូច្នោះដែរ។ យ៉ាងណាក៏ដោយក្នុងការអង្កេតលើពលកម្មកុមារគួរតែធ្វើឱ្យគេចាប់អារម្មណ៍ក្នុងការកត់ត្រាគំនិត ឬអារម្មណ៍របស់អ្នកឆ្លើយ ដែលអាចលើកឡើង។

សកម្មភាពអង្កេតគឺត្រូវរៀបចំសម្របសម្រួលនឹងធ្វើគម្រោងឱ្យបានល្អ។ ក្រុមត្រូវតែរកពេល និងរៀបចំធ្វើការអង្កេត។ ប្រសិនបើការកត់សម្គាល់មុនៗត្រូវផ្តល់ឱ្យនរណាម្នាក់ ឧទាហរណ៍ : ឱ្យនាយកសាលា និងគ្រូបង្រៀនប្រសិនបើបានធ្វើការអង្កេតក្នុងបរិស្ថានសាលាមួយនេះគួរតែធ្វើក្នុងពេលដ៏សមគួរ។ ឱ្យក្រុមទាំងអស់ដំណើរការលេងល្បែងស្ទង់មតិមួយៗហើយសរសេរលទ្ធផលនៃការពិភាក្សាគួរតែពឹងផ្អែកលើគោលការណ៍ទាំងប្រាំរបស់សំណួរបើកដូចជា : អ្នកណា? អ្វី ទៅ? ពេលណា? កន្លែងណា? ហេតុអ្វី ?

- អ្នកណាត្រូវបានអង្កេត ហើយអ្នកណាជាអ្នកធ្វើការអង្កេត ឧទាហរណ៍ : សម្ភាសន៍ក្រុមមុខសញ្ញាឬផ្តល់ និងប្រមូលកម្រងសំណួរមកវិញ។
- តើត្រូវធ្វើការស្ទាបស្ទង់មតិតាមរូបភាពបែបណា? តាមការសម្ភាសន៍ ឬការបំពេញសំណួរ។
- តើពេលណាត្រូវដឹកនាំការស្ទាបស្ទង់មតិ ហើយពេលណានឹងទទួលលទ្ធផល?
- តើយើងដឹកនាំការស្ទាបស្ទង់មតិនៅកន្លែងណា?
- ហេតុអ្វីបានជាត្រូវធ្វើការស្ទង់មតិ? ប្រសិនបើការស្ទង់មតិផ្អែកទៅលើការបំពេញកម្រងសំណួរ ក្រុមគួរតែសម្រេចរកពេលផ្តល់កម្រងសំណួរ និងប្រមូលមក វិញតាមរបៀបណា?

សង្ឃឹមថារយៈពេលនៃការស្ទង់មតិគឺ មិនត្រូវឱ្យអ្នកឆ្លើយចំណាយពេលច្រើនទេ។ ឧទាហរណ៍ ប្រសិនបើអ្នកកំពុងធ្វើការនៅបរិស្ថានសាលាមុខសញ្ញាអាចជាថ្នាក់ណាមួយឬ ឆ្នាំណាមួយបន្ទាប់ពីការពិភាក្សាជាមួយនាយក និងគ្រូទាំងអស់ក្នុងសាលាដែលពាក់ព័ន្ធបញ្ជីសំណួរអាចចែកនៅពេលព្រឹកគឺពេលចូលរៀន បន្ទាប់មកប្រមូលមុនចេញទៅផ្ទះ ពេលថ្ងៃត្រង់ ឬក៏ពេលល្ងាចចេញទៅផ្ទះ។ ការងារនេះអាចធ្វើបានដោយការសហការគ្នារបស់បុគ្គលកែសាលារៀន។ គោលការណែនាំលើការដឹកនាំល្បែងស្ទង់មតិម្តងមួយហើយ និងសម្ភាសន៍មាននៅក្នុងផ្នែកឯកសារបន្ថែមទី១ ។

វិភាគការអង្កេត

កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

លក្ខណៈនៃការស្ទាបស្ទង់មតិមានដំណើរការស្មុគស្មាញ មិនតែប៉ុណ្ណោះលក្ខណៈនៃការស្រាវជ្រាវគឺជាមុខរបរវិជ្ជាជីវៈហើយកាលវិភាគស្ថិតិដែលគេតម្រូវវឱ្យអាចប្រហាក់ប្រហែលគ្នានឹងកិច្ចការដែលលំបាកសម្រាប់មនុស្សវ័យក្មេងអាចយល់។ ទោះជាយ៉ាងណាក៏ដោយកុំផ្តល់ក្តីសង្ឃឹមខ្ពស់ទៅលើកិច្ចការ ដឹងច្បាស់ថាក្រុមនៅតែមានគំនិតអភិរក្សផ្តោតលើការស្ទាបស្ទង់មតិរបស់ក្រុម និងការរៀបចំ។ នេះជាមូលហេតុនៃកម្រងសំណួរស្ទង់មតិលើក្រដាសមួយ ឬពីរទំព័រជាចំនួនអតិបរមា ប្រសិនណាសំណួរទាក់ទងត្រង់ៗ ហើយឆ្លើយតបនឹងសំណួរជ្រើសរើស នៅចុងបញ្ចប់នៃការវិភាគមិនពិបាកណាស់ណាទេ។

នៅពេលការស្ទាបស្ទង់មតិបានធ្វើរួចហើយ លទ្ធផលក៏ត្រូវបានប្រមូលតាមក្រុម អ្នកគួរតែរៀបចំប្រមូលក្រុមដើម្បីពិភាក្សាជំហានបន្តទៀតនោះគឺកាលវិភាគ។

អាស្រ័យទៅលើការស្ទាបស្ទង់មតិ ដែលបានធ្វើជាមួយក្រុមមុខសញ្ញា អ្នកគួររៀបចំសម្រាប់វិភាគធ្វើឡើង បុគ្គលដែលដឹកនាំការស្ទាបស្ទង់មតិផ្សេងទៀត។ វាមានសារៈសំខាន់ខ្លាំងណាស់ដែលគេបង្កើតស្មារតីម្ចាស់ការ និងមានមោទនភាពចំពោះការងារ ហើយដែលគេបានដឹងអំពីការជឿជាក់ដែលអ្នកមានចំពោះពួកគេ និងចំពោះលទ្ធភាពរបស់ពួកគេ។ក៏មានន័យថានៅពេលដែលគេសរសេរលទ្ធផលនៃការស្ទាបស្ទង់មតិចប់ជាស្ថាពរ ឈ្មោះរបស់គេត្រូវបានសរសេរនៅខាងក្រោយនៃទំព័រស្បៃវរភៅដូចជាក្រុមស្រាវជ្រាវដែលបានធ្វើការងារនេះ ។ វានឹងផ្តល់នូវការជំរុញមួយដ៏សំខាន់ឆ្ពោះទៅរកការគោរពខ្លួនឯង ការទុកចិត្ត និងចុងបញ្ចប់ផ្តល់ការសន្យាប្តេជ្ញាសម្រេចដូចគម្រោងនេះ ។

ប្រសិនបើអ្នកណាម្នាក់ជួយអ្នកក្នុងការស្ទាបស្ទង់មតិ ហើយអ្នកនោះជាអ្នកស្រាវជ្រាវស្ថិតិវាជាការល្អណាស់ដើម្បីស្នើសុំមនុស្សនោះឱ្យជួយក្នុងការសរសេរលទ្ធផល។ អ្នកគួររៀបចំក្រុមផ្សេងៗឱ្យរួមគ្នាក្នុងបន្ទប់ដែលអ្នកធ្វើការ។ ប្រសិនបើគេធ្វើនៅជុំវិញតុដែលនៅដាច់ពីគ្នានោះគឺរឹតតែប្រសើរ។ គួរតែបានលទ្ធផលពីការឆ្លើយតបនៃការស្ទាបស្ទង់មតិនៅចំពោះមុខគេ។

ប្រាប់គេថា បន្ទាប់មកទៀតគឺត្រូវសង្ខេបពត៌មានដែលគេទទួលបាននៅក្នុងតារាងក្រាហ្វិក និងទម្រង់សរសេរ។

- **តារាងក្រាហ្វិក និងដ្ឋង់ក្រាយ :**

ប្រសិនបើសំណួរព្រាងជាសំណួរជ្រើសរើស វាអាចឆ្លើយជាចម្លើយនៅក្នុងតារាង ឬក៏ក្រាហ្វិក ឧទាហរណ៍ bar charts or pie charts មានចន្លោះមួយបង្ហាញពីចំនួនចម្លើយចាស់ ឬបាទ ហើយចន្លោះមួយទៀតបង្ហាញពីពាក្យថាទេ ឬមិនដឹងទេ។ ប្រសិនបើអ្នកអាចប្រើកុំព្យូទ័រ (ប្រហែលជាក្នុងសាលា ឬនៅក្នុងបណ្ណាល័យ) ហើយអ្នកមានពេល និងបទពិសោធន៍ ឬជំនួយពីខាងក្រៅលទ្ធផលទាំងនេះអាចចេញមកនៅក្នុងសន្លឹកក្រដាសកម្មវិធីដើម្បីធ្វើឱ្យរបាយការណ៍បញ្ចប់មើលទៅមានលក្ខណៈវិជ្ជាជីវៈថែមទៀត ទោះបីយ៉ាងណាក៏ដោយវាដំណើរការល្អ ដើម្បីបង្កើតវានៅលើប្រអប់ក្រដាសបួនជ្រុងប្រើពណ៌។ ចូរប្រាប់ក្រុមថាគេគប្បីរៀបរាប់ភាពពិស្តារនៅក្នុងកញ្ចប់ ឬតារាងសម្រាប់អ្នកអាន។ នេះគួរតែបញ្ចូលចំណងជើងទៅលើសំណួរនីមួយៗ ដែលបានសួរ ។

- **របៀបសរសេរ :**

សំណួរខ្លះជាពិសេសដូចជាមុខវិជ្ជាដែលចាប់អារម្មណ៍ដូចជាពលកម្មកុមារ និងការស្នើសុំគំនិត និងទស្សនៈរបស់អ្នកឆ្លើយតប។ ទាំងនេះអាចសង្ខេបក្នុងរបាយការណ៍របស់បុគ្គលិកម្នាក់ៗនៃក្រុមដែលមានតំណាង និងគំនិតល្អនូវរបៀបសង្ខេបមេរៀន ប៉ុន្តែពួកគេត្រូវការជំនួយពីលោកអ្នក ឬពីធនធានមនុស្ស។ ពន្យល់ពួកគេថាគំនិតនោះមិនធ្វើឡើងដោយត្រង់ៗនូវអ្វីដែលមនុស្សបាននិយាយទេ ប៉ុន្តែស្រង់ចេញហើយបញ្ចាក់បន្ថែមទៅលើមតិរួមដែលគេផ្តល់ដោយមនុស្សច្រើន។ ប្រាប់ពួកគេបញ្ចូលការដកស្រង់សំដី ប្រសិនបើការឆ្លើយតបមួយចំនួនមានការពាក់ព័ន្ធជាពិសេស។

របាយការណ៍គួរផ្តល់ប្រវត្តិព័ត៌មានខ្លះៗស្តីអំពីការសង្កេតពីដំបូង។ ពិចារណាឱ្យដិតដល់ទៅគឺសំដៅដល់ 5 WS [1] ដែលលើកឡើងមុននេះ។ បន្ទាប់មកពួកគេគួរតែយល់ច្បាស់ថា ផ្នែកនិមួយៗត្រូវចងភ្ជាប់គ្នា និងបង្កើតលំហូរឥតដាច់ និងបែបធម្មជាតិនៃព័ត៌មាន។ ពួកគេគួរតែសរសេរផ្នែកបញ្ចប់ដែលពួកគេបានលើកចំនុចសំខាន់ៗ ហើយពណ៌នានូវអ្វីដែលពួកគេបានគិតថាការស្ងង់មតិសម្រេចបាន។

ប្រាប់ក្រុមដែលគេមិនបានរុញរានឹងកិច្ចការ គួរតែសរសេរសង្ខេបពីការប៉ុនប្រសប់របស់ពួកគេដោយយកចិត្តទុកដាក់។ ដើរជុំវិញក្រុមដែលពួកគេកំពុងពិភាក្សាគូសប្រអប់ឬតារាង ហើយសរសេររៀបរាប់ពីរបាយការណ៍របស់ពួកគេ។ ពិនិត្យឱ្យច្បាស់ថាមនុស្សគ្រប់គ្នាកំពុងចូលរួមក្នុងរបៀបមួយ ឬរបៀបផ្សេងទៀត។ ជួយរៀបពាក្យពួកគេពីអ្វី

ដែលពួកគេចង់ជួយបញ្ចូលស្ថិតិ និងគួសប្រអប់។ ប្រសិនបើអ្នកដើរជុំវិញពួកគេ ហើយអ្នកឃើញក្រុមខ្លះដែលប៉ិនប្រសប់ខាងគួសប្រអប់ និងតារាងឬប៉ិនប្រសប់ខាងសង្ខេបព័ត៌មាន និងការបង្ហាញខ្លួនតាមរយៈការសរសេរ។ សួរបុគ្គលិកទាំងនេះក្រែងលោគេសុខចិត្តជួយក្រុមផ្សេងទៀតដែលប្រហែលជាមានការពិបាកក្នុងការដាក់បញ្ចូលរបាយការណ៍របស់ពួកគេឱ្យចូលគ្នា ។

ជាថ្មីម្តងទៀត បើអ្នកប្រើប្រាស់កុំព្យូទ័របាន ក្រុមទាំងអស់អាចវាយរបាយការណ៍និងបញ្ចូលក្រាហ្វិកក្នុងតារាងឯកសារ Word ។ ប្រសិនបើអ្នកមិនចេះប្រើប្រាស់កុំព្យូទ័រខ្លួនឯងទេ អ្នកស្គាល់អ្នកណាម្នាក់អាចជួយផ្នែក នេះហើយបង្រៀនក្រុមនូវរបៀបធ្វើដោយខ្លួនឯង ពួកគេអាចរៀនច្រើនអំពីការបង្ហាញរបាយការណ៍តាមរយៈលំហាត់នេះហើយនឹងបង្កើតចំណេះដឹងទូទៅ និងការអភិវឌ្ឍបុគ្គលិកលក្ខណៈប្រសិនបើអ្នកមិនចេះប្រើប្រាស់កុំព្យូទ័រត្រូវពិនិត្យឱ្យច្បាស់ថា តើអ្នកដែលអាចសរសេរច្បាស់លាស់ត្រូវសរសេរឡើងវិញរៀបរាប់នូវរបាយការណ៍ចុងបញ្ចប់។ តារាង និងប្រអប់អាចកាត់ចេញ ហើយឥតចម្លងដាក់ក្នុងទំព័រសរសេរ។ នៅពេលដែលពួកគេបានបញ្ចប់របាយការណ៍រួចរាល់សមាជិកម្នាក់ៗត្រូវចុះហត្ថលេខា ហើយដាក់ឈ្មោះនៅខាងក្រោមផ្នែកសេចក្តីបញ្ចប់កុំបីខាន។

សកម្មភាពបន្ត

ក្រោយពីបានបំពេញរបាយការណ៍រួចរាល់ ហេតុអ្វីបានជាគេមិនចែករំលែកលទ្ធផលជាមួយនឹងអ្នកផ្សេងយ៉ាងហោចណាស់ជាមួយអ្នកដែលចូលរួមក្នុងការស្ទង់មតិនេះដោយផ្អែកទៅលើបរិបទនៃការងារដែលអ្នកកំពុងធ្វើ អ្នកប្រហែលជាចង់ផ្សព្វផ្សាយរបាយការណ៍នៅក្នុងសាលាសហគមន៍។ ចូរទាក់ទងទស្សនាវដ្តីរបស់សាលា ឬព្រឹត្តប័ត្រព័ត៌មានក្នុងស្រុក ឬប្រព័ន្ធផ្សព្វផ្សាយធំៗ។ លទ្ធផលនឹងមានន័យសម្រាប់អ្នកផ្សេងទៀត។ ពួកគេនឹងចាប់អារម្មណ៍ចង់ដឹងពីលទ្ធផល ហើយវាបានផ្តល់នូវការជំរុញដ៏សំខាន់មួយឆ្ពោះទៅរកការទុកចិត្តនឹងមោទនភាពរបស់មនុស្ស ក្មេងៗនៅក្នុងក្រុមរបស់អ្នកដែលដឹងថាអ្នកផ្សេងទៀតនៅក្នុងសហគមន៍កំពុងតែអានរបាយការណ៍ពួកគេនឹង ចាប់អារម្មណ៍នូវអ្វីដែលមាននិយាយក្នុងរបាយការណ៍។ ចូរស្នើយោបល់ទៅកាន់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក ឬប្រព័ន្ធ ផ្សព្វផ្សាយជាតិថាក្រុមសរសេរអត្ថបទសម្រាប់ការបោះពុម្ពដែលមានខ្លះត្រូវពឹងផ្អែកទៅលើលទ្ធផលនៃការស្ទាបស្ទង់មតិរបស់ពួកគេ(ចូរអានប្រព័ន្ធផ្សព្វផ្សាយជំពូកព័ត៌មានសម្រាប់គំនិត)។ វាអាចថាផ្នែកមួយនៃការស្ទាបស្ទង់មតិ និងមានស្តង់ដាខ្ពស់ ហើយអ្នកគួរតែមានសេចក្តីប្រាថ្នាខ្ពស់សម្រាប់ក្រុមរបស់អ្នក។ យកលទ្ធផលទៅផ្សព្វផ្សាយទៅសហគមន៍ធំ។ នេះជាទិសដៅនៃលំហាត់ ដើម្បីជួយមនុស្សវ័យក្មេងទាំងនេះអប់រំអ្នកផ្សេងទៀតធ្វើជាភ្នាក់ងារផ្លាស់ប្តូរសង្គម។ ការគិតជាក្រុមនូវអ្វីដែលប្រើប្រាស់ក្នុងរបាយការណ៍ទាំងនេះប្រហែលជាត្រូវកសាងនូវទម្រង់ផ្សេងៗនៃការងារបន្តក្រោយទៀត ។

ចូរចងចាំថារបាយការណ៍នៃការស្ទាបស្ទង់មតិ នឹងមានសារៈសំខាន់ក្នុងម៉ូឌុលបន្តបន្ទាប់ដូចជា : ម៉ូឌុលប្រព័ន្ធផ្សព្វផ្សាយមានពីរ និងជំពូកការសរសេរប្រកបដោយច្នៃប្រឌិត។ ថែរក្សាម៉ូឌុលខាងលើនេះឱ្យមានសុវត្ថិភាព ។ មនុស្សផ្សេងទៀតនឹងចាប់អារម្មណ៍អានឯកសារទាំងនោះ ជាពិសេសរបាយការណ៍នៃការស្ទាបស្ទង់មតិទាំងនេះនឹងមានសារៈសំខាន់នៅមេរៀនខាងមុខក្នុងម៉ូឌុលនេះគឺ ការសម្ភាសន៍ម្នាក់ម្តងធ្វើឱ្យក្រុមអាចទាក់ទងអ្នកតំណាងសហគមន៍ ដើម្បីអូសទាញពួកគេឱ្យចូលរួមពិភាក្សាអំពីពលកម្មកុមារ។ ប្រសិនបើពួកគេទាក់ទងទៅលើកំណើនស្ថិតិស្តីពីការស្ទង់មតិដែលពួកគេបានធ្វើនោះ វានឹងជំរុញឱ្យប្រសើរឡើងខ្លាំងក្លាថែមទៀតនូវភាន:របស់ពួកគេបើប្រៀបធៀបទៅនឹងអ្នកដែលត្រូវគេសម្ភាសន៍។

សកម្មភាព ២ : ការសម្ភាសន៍ម្នាក់ៗ

បង្រៀន២ទៅពាដងមេរៀន :

បច្ចេកទេសខ្លះបានពិភាក្សាក្នុងវគ្គមុនក៏មានការពាក់ព័ន្ធនៅក្នុងទីនេះផងដែរ។ ក្នុងមេរៀននេះការសម្ភាសន៍ នឹងផ្តោតទៅលើមនុស្សម្នាក់ ឬមនុស្សច្រើនមកពីសហគមន៍ណាមួយ ឧទាហរណ៍ : អ្នកនយោបាយ អ្នកគ្រប់គ្រងហាង និងមានទិសដៅអាចស្វែងយល់នូវអ្វីដែលសមាជិករបស់សហគមន៍ណាមួយអាចធ្វើ និងកំពុងធ្វើ ដែលទាក់ទងនឹងពលកម្មកុមារនឹងទំហំនៃការយល់ដឹងអំពីបញ្ហារបស់ពួកគេ។ វាអាចជាផ្នែកមួយនៃការស្ទាបស្ទង់មតិដ៏ធំទូលំទូលាយ ដែលដៅយកអ្នកដឹកនាំសហគមន៍ទាំងនេះជាមុខសញ្ញានៅក្នុងករណីនេះ ។ អ្នកនឹងសួរសំណួរដែលៗសម្រាប់អ្នកឆ្លើយក្នុងការស្ទង់មតិ។ ទោះជាយ៉ាងណាក៏ដោយអ្នកប្រហែលជាពេញចិត្តសម្ភាសន៍បុគ្គលទាំងនេះម្តងមួយៗ។ ទាំងអស់នេះវាអាស្រ័យទៅលើអ្នក និងក្រុម។ ហើយវាអាចអាស្រ័យលើទំហំនៃការទទួលបានធនធាន និងតំណាងសហគមន៍ខ្លះដែលអាចចូលដល់ ។

ចូរប្រជុំក្រុមនៅក្នុងបន្ទប់ប្រជុំ ឬថ្នាក់រៀននិងពិភាក្សាអំពីគោលបំណង និងទិសដៅនៃការសម្ភាសន៍ទាំងឡាយដូចជាសេចក្តីផ្តើមចំពោះការពិភាក្សាជាមួយមនុស្សដែលគេគួរសម្ភាសន៍។ គោលបំណងចែកចេញជាបីដូចតទៅ :

- ដើម្បីប្រាប់សហគមន៍ផ្សេងទៀតឱ្យដឹងអំពីសកម្មភាពនៃគម្រោង និងបញ្ហាពលកម្មកុមារ ។
- ដើម្បីបន្តដំណើរការស្រាវជ្រាវនូវកម្រិតយល់ដឹង ដែលមានស្រាប់នៅក្នុងសហគមន៍ផ្សេងគ្នា និងអ្វីដែលយើងបានធ្វើរួចរាល់ ដើម្បីបន្តយុទ្ធនាការណ៍លុបបំបាត់ពលកម្មកុមារ។
- ដើម្បីបញ្ចុះបញ្ចូលឱ្យមានការគាំទ្រដល់គម្រោង និងយុទ្ធនាការពីសំណាក់មនុស្សសំខាន់ដែលជំនួសមុខឱ្យសហគមន៍។

ពិភាក្សាលើគោលបំណងទាំងបីនេះជាមួយក្រុម ហើយពង្រីកវាឱ្យកាន់តែពិស្តារ។ វាជាការសំខាន់ដែលពួកគេយល់នូវគោលបំណងនេះ ព្យាយាម និងជំរុញទឹកចិត្តពួកគេឱ្យបង្ហាញមតិឱ្យបានច្រើនដែលអាចទៅបានតាមរយៈដំណើរការគិតរបស់ពួកគេដែលគេនឹងយល់ពីគោលបំណងបានល្អជាងនេះ ហើយដូច្នេះគេបានជួយគាំទ្រ ដល់ការអនុវត្តរបស់ពួកគេ។

កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

ប្រសិនបើអ្នកមិនអនុវត្តមេរៀនការស្ទាបស្ទង់មតិជំពូកនេះ អ្នកនឹងត្រូវពិភាក្សាលំហាត់សម្ភាសន៍ក្នុងក្រុម។ ប្រើ "បច្ចេកទេសនៃការសម្ភាសន៍ម្តងមួយ៧" ដែលបានពិពណ៌នាក្នុងឧបសម្ព័ន្ធទី១ ដើម្បីជួយអ្នកក្នុងដំណើរការនេះ។

ការជ្រើសរើសបេក្ខជន

មុនពេលដែលអ្នកអាចឈានជើងចូលរៀបចំសម្រាប់សម្ភាសន៍ខ្លួនឯង ហើយនិងសំណួរដែលត្រូវសួរ អ្នកនិងក្រុមត្រូវការគិតយ៉ាងប្រុងប្រយ័ត្នអំពីមនុស្សដែលអ្នកចង់សម្ភាសន៍ហើយហេតុអ្វី។ ដឹកនាំធ្វើសកម្មភាពពិភាក្សារកគំនិតរួមក្នុងគោលបំណងរកឱ្យឃើញនូវបុគ្គលម្នាក់ ឬ មួយចំនួនដែលគេជ្រើសរើសនៅក្នុងសហគមន៍ដែលមានសារៈសំខាន់ដើម្បីសម្ភាសន៍។ ត្រូវជ្រើសរើសបុគ្គលទាំងឡាយណាដោយផ្អែកទៅលើមូលដ្ឋាន ដែលថាពួកគេនឹងត្រូវបន្តបុព្វហេតុរបស់ក្រុម និងគម្រោងរបស់ពួកគេ ហើយនិងមិនថយក្រោយ។ ចូរកុំប្រើប្រាស់សមត្ថភាពរបស់ក្រុមឱ្យជ្រុលខ្លាំងពេកក្នុងការធ្វើលំហាត់នេះ អាចនិយាយបានម្យ៉ាងទៀតថាការសម្ភាសន៍ពីរ ឬ បីដងគួរតែសមល្មម និងអាចងាយផ្សព្វផ្សាយទៅតាមពេលវេលាមួយជាជាងកើតឡើងបន្តបន្ទាប់គ្នាមួយហើយមួយទៀត។

កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

ក្រុមមិនចាំបាច់ធ្វើការសម្ភាសន៍ជាមួយនឹងនរណាម្នាក់ដែលរារែកទៅលើកម្មវិធី ។បទពិសោធន៍បង្ហាញថាវាសំខាន់ណាស់ដែលអញ្ជើញអ្នកដឹកនាំសហគមន៍ទាំងឡាយមកប្រជុំក្រុម និងពិភាក្សាប្រភេទនៃគម្រោងជាមួយពួកគេ។ ពួកគេអាចអញ្ជើញទៅដើម្បីស្តាប់កិច្ចពិភាក្សាតទល់ ឮការអានជាសាធារណៈនៃការសរសេរប្រកបដោយគំនិតច្នៃប្រឌិត មើលល្ខោន មើលការសម្តែងសិល្បៈដ៏ប៉ិនប្រសប់នៃពលកម្មកុមារ។ ល។ និង។ ល។ ដោយត្រូវបានគេផ្តល់នូវលក្ខណៈនៃគម្រោងតំណាងឱ្យសហគមន៍ទំនងជាមិនបដិសេធនូវការអញ្ជើញនេះទេ។ ការសម្ភាសន៍អាចត្រូវរាប់បញ្ចូលទុកជាផ្នែកនៃការអញ្ជើញចូលរួមនេះ។ ឧទាហរណ៍ : ប្រសិនបើអ្នកនយោបាយក្នុងស្រុកម្នាក់បានអញ្ជើញមកសង្កេតកិច្ចពិភាក្សាតទល់ដែលធ្វើឡើងដោយក្រុមវាអាចជាជំហានធម្មតាដើម្បីសម្ភាសន៍មនុស្សនេះ សំដៅស្វែងយល់អំពីប្រតិកម្មរបស់ពួកគេចំពោះការពិភាក្សាតទល់នឹងគម្រោងនេះ។ កិច្ចសម្ភាសន៍ក៏បានបញ្ចូលទាំងសំណួរផងដែរអំពីអ្វីដែលអ្នកនយោបាយកំពុងធ្វើអំពីពលកម្មកុមារ និងអារម្មណ៍យ៉ាងដូចម្តេចចំពោះការគាំទ្រយុទ្ធនាការដ៏ទូលំទូលាយ ដើម្បីលុបបំបាត់ពលកម្មកុមារ។ មនុស្សនោះក៏ប្រហែលជាចូលចិត្តនិយាយអំពីគម្រោងក្នុងសហគមន៍របស់ពួកគាត់ផ្ទាល់ និងជួយលើកកម្ពស់សកម្មភាពរបស់ក្រុមទៀតផង។ នេះគឺជាទម្រង់នៃការបញ្ចូលគ្នារបស់សហគមន៍ និងការលើកកម្ពស់ចំណេះដឹង ហើយវាគឺជាដំណើរការផ្តល់សិទ្ធិអំណាចសម្រាប់ក្រុមយ៉ាងសំខាន់ ។

មានក្រុមធំៗចំនួនប្រាំដែលអ្នកប្រហែលជាចាត់ទុកពួកគេថាជាអ្នកសម្ភាសន៍ដែលមានសក្តានុពល។ ក្រុមនីមួយៗមានការទាក់ទង និង ផលប្រយោជន៍សម្រាប់ហេតុផលផ្សេងៗគ្នាដូចតទៅ :

- អំណាច : ទាំងនេះប្រហែលជារាប់បញ្ចូលតំណាងឱ្យរដ្ឋាភិបាលក្នុងស្រុក និង ថ្នាក់កណ្តាល អ្នកនយោបាយ អ្នករដ្ឋការក្នុងស្រុកក្រុមសកម្មជនខាងគណបក្សនយោបាយ អ្នកតំណាងឱ្យសហគមន៍អន្តរជាតិ ។ល។
- និយោជក : តួនាទីរបស់អ្នកជំនួញគ្រប់ប្រភេទដែលមានការទាក់ទងនឹងពលកម្មកុមារគឺសំខាន់ណាស់ ជានិច្ចកាលវាជាលំហាត់ដែលគួរឱ្យចាប់អារម្មណ៍ ដើម្បីជជែកទៅកាន់អ្នកគ្រប់គ្រងហាងម្ហូសរោងចក្រ អ្នកគ្រប់គ្រងក្រុមហ៊ុនដឹកជញ្ជូននិងអ្នកផ្សេងទៀតអំពីបញ្ហាពលកម្មកុមារ និងវិធានការអ្វីខ្លះដែលគេត្រូវអនុវត្តដើម្បីធានាឱ្យច្បាស់ថាទំនិញដែលពួកគេលក់ត្រូវបានធ្វើឡើង ក្រោមលក្ខខ័ណ្ឌការងារដ៏សមស្រប។
- អង្គការសហគមន៍ : ទាំងនេះអាចបញ្ចូលសហជីពពាណិជ្ជកម្ម និងអង្គការក្រៅរដ្ឋាភិបាល ដែលពួកគេមួយចំនួន និងដំណើរការសកម្មភាពក្នុងផ្នែកពលកម្មកុមារ។ សហជីពពាណិជ្ជកម្មត្រូវដើរតួជាក់ស្តែងក្នុងកន្លែងការងារនេះ ប៉ុន្តែអង្គការក្រៅរដ្ឋាភិបាលខ្លះ និងសប្បុរសជនក៏ធ្វើការច្រើនដែរដើម្បីព្យាយាមជួយការងារកុមារពលកម្ម និងគ្រួសាររបស់ពួកគេ។
- មនុស្សល្បីល្បាញ : មានសាលាពីរបានគិតទៅដល់ការចូលរួមរបស់មនុស្សល្បីល្បាញក្នុងគម្រោងប្រភេទនេះ។ សាលាមួយទាមទារឱ្យលក្ខណៈនៃគម្រោងបញ្ចូលមនុស្សដែលល្បីមកពាក់ព័ន្ធ ហើយជននោះជាអ្នកមាន និងរស់នៅក្នុងទីកន្លែងផ្សេងគ្នា។ សាលាទីពីរគឺមានជំនួយពីណាក៏ដោយដែលអាចទាក់ទាញបានសម្រាប់គម្រោងបែបនេះគួរតែទទួលស្វាគមន៍។ សារៈប្រយោជន៍មួយនៃការចូលរួមពីមនុស្សល្បីពិតជាបង្កើតឱកាសសម្រាប់គម្រោងដោយទាក់ទាញប្រព័ន្ធផ្សព្វផ្សាយនិងទាញអារម្មណ៍សាធារណជន។ អ្នកនិងក្រុមរបស់អ្នកគួរតែសម្រេចចិត្តតើត្រូវដាក់ការពេញចិត្តរបស់ខ្លួននៅត្រង់ណា?

- បុគ្គលដែលពាក់ព័ន្ធ : នេះអាចបញ្ចូលអ្នកស្រាវជ្រាវដែលចាប់អារម្មណ៍នៅក្នុងបញ្ហាពលកម្មកុមារ អ្នកនិពន្ធ សិល្បករ ឪពុកម្តាយ សមាជិក ក្រុមសាធារណជនទូទៅ និងមនុស្សវ័យក្មេងផ្សេងទៀត។ល និង។ល។ លំហាត់គួរឱ្យចាប់អារម្មណ៍ គឺត្រូវសម្ភាសន៍អ្នកតំណាងម្នាក់មកពីក្រុមនីមួយៗ។ ក្រុមប្រហែលជាចង់សម្ភាសន៍ តាមលំដាប់ជាមួយមនុស្សម្នាក់ ក្រុមនីមួយៗ ឬការជ្រើសរើសក្រុមមួយវិញទៀតការងារច្រើនគឺអាស្រ័យទៅលើអ្នក និងក្រុមភាពស្វាហាប់របស់ក្រុមឱកាសដែលអាចមាននៅក្នុងប្រទេសផ្សេងៗ និងការកំណត់ធនធានដែលអាចរកបាន។ល។ និង។ល។ ត្រូវចាំថាមនុស្សមួយចំនួន នៅក្នុងតារាងរបស់អ្នកប្រហែលជាមិនអាចទទួលការអញ្ជើញទៅសម្ភាសន៍បានទេ ដូច្នេះហើយត្រូវមានបេក្ខជនបម្រុងសម្រាប់សម្ភាសន៍ជាយថាហេតុ។

កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

ប្រសិនអាចចូលទទួលយកការប្រើប្រាស់ម៉ាស៊ីនថតវីដេអូសម្រាប់លំហាត់នេះវានឹងអាចចាប់អារម្មណ៍ផង និងការអប់រំផង ដើម្បីថតការសម្ភាសន៍។ ការចាក់បង្ហាញឡើងវិញនៅតំណាក់ក្រោយៗអាចផ្តល់ការរីករាយបន្តិច និងការកំសាន្តសម្រាប់ក្រុម។ ប៉ុន្តែវាថែមទាំងជួយអ្នកនិងធនធានមនុស្សពីក្រៅក្នុងការបង្រៀនបច្ចេកទេសសម្ភាសន៍ដល់ក្រុមទៀតផង។ លើសពីនេះទៅទៀត វាអាចផ្តល់នូវការមើលឯកសារអំពីលទ្ធផលរបស់ការសម្ភាសន៍ដែលអាចជក់ចិត្តសម្រាប់សមាជិកនៃក្រុមដែលមិនបានចូលរួមដោយផ្ទាល់។ ឯកសារដែលវែងគួរតែរក្សាទុកព្រោះថាវានឹងធ្វើឯកសារអំពីដំណើរការរីកចំរើននៃគម្រោងរបស់អ្នក។

ទំនាក់ទំនងជាមួយបេក្ខជន

នៅពេលដែលអ្នកបានបញ្ចប់លំហាត់បំផុសគំនិតរួម និងបានបង្កើតការជ្រើសរើសបេក្ខជនដែលមានលទ្ធភាពសម្រាប់ការសម្ភាសន៍នៅជំហានបន្ទាប់គឺ ត្រូវសម្រេចចិត្តជាមួយក្រុមថាតើការសម្ភាសន៍នេះត្រូវធ្វើបែបណា តើការសម្ភាសន៍នេះនឹងត្រូវធ្វើឡើងជាលំហាត់ដាច់ដោយឡែកមួយ ឬ ក៏ជាផ្នែកនៃការអញ្ជើញឱ្យចូលរួមក្នុងសកម្មភាពដែលបានធ្វើឡើងដោយក្រុម ដូចជាការជជែកតទល់ជាដើម នេះពិតជាការសម្រេចចិត្តដ៏សំខាន់ព្រោះវាអាចជះឥទ្ធិពលទៅលើសំបុត្រដែលបានផ្ញើទៅអ្នកដែលជាប់ពាក់ព័ន្ធ។

អ្នកនិងក្រុមត្រូវសរសេរសេចក្តីណែនាំដំបូងឱ្យបានល្អផ្ញើទៅឱ្យអ្នកដែលគេសម្ភាសន៍ ដោយប្រាប់គេអំពីគម្រោងនិងពន្យល់ពីអ្វីដែលអ្នកកំពុងប្រឹងប្រែងសុំពីគេ។ សំបុត្រគំរូជាសេចក្តីបន្ថែមដើម្បីជួយក្នុងដំណើរការនេះ។ ប្រាកដហើយខ្លឹមសារ អាស្រ័យទៅលើបុគ្គលដែលពាក់ព័ន្ធ វាក៏អាចខុសប្លែកដោយសារប្រភេទនៃការអញ្ជើញ
ឧទាហរណ៍ : តើក្រុមចង់សុំត្រឹមតែសម្ភាសន៍ ឬក៏ការសម្ភាសន៍នេះនឹងត្រូវធ្វើឡើងក្នុងបរិបទនៃសកម្មភាពរបស់ក្រុម?

មូលដ្ឋានច្បាប់សម្រាប់សំបុត្រគឺ :

- កាន់តែខ្លីកាន់តែល្អ
- ចេះគួរសម
- ត្រូវឱ្យចំចំណុចគោលដៅ
- សុំការឆ្លើយតប
- បញ្ចូលឈ្មោះ និងអាស័យដ្ឋានសម្រាប់ការទទួលការឆ្លើយតបពិពណ៌នាពីប្រវត្តិរបស់គម្រោងប្រើគោលការ 5w's ដែលត្រូវគេលើកឡើងមុននេះ។

សំបុត្រអាចសរសេរដោយក្រុមទាំងមូលនៅក្នុងថ្នាក់ ឬ ប្រសិនបើមានការសម្ភាសន៍បេក្ខជនច្រើននាក់ ដែលក្នុងពេលនោះត្រូវបានគេចាត់ជាមុខសញ្ញានៅក្នុងក្រុមតូចៗ។ សរសេរលើក្តារខៀន ឬផ្ទាំងរូបភាពដែលអាចបត់បានអំពីសារៈប្រយោជន៍របស់សំបុត្រ។ ដូច្នេះហើយក្រុមតូចៗនីមួយៗអាចធ្វើតាមនេះក្នុងការចូលរួមធ្វើលំហាត់ធ្វើសកម្មភាពក្នុងចំណោមក្រុម និងជួយពួកគេជាមួយនឹងសំបុត្រ ។

ប្រសិនបើក្រុមផ្សេងទៀតសរសេរសំបុត្របានល្អប្រសើរ សំបុត្រនេះជាគំរូដើម្បីជួយអ្នកផ្សេងទៀត ប្រសិនបើកុំព្យូទ័រអង្គុលីលេខអាចប្រើការបានប្រើវា ដើម្បីវាយកែចុងបញ្ចប់នៃសំបុត្រ ឬអ្នកចង់ទាក់ទងដោយផ្ទាល់ និង សួរអ្នកណាម្នាក់នៅក្នុងក្រុមដែលសរសេរបានល្អ ដើម្បីចម្លងសំបុត្រប្រកបដោយរបៀបរៀបរយ។

សំបុត្រនីមួយៗគួរតែចុះហត្ថលេខាដោយសមាជិកក្រុមទាំងអស់ហើយបញ្ចូលឈ្មោះអប់រំផង។ នេះគឺជាគម្រោងរបស់ក្រុម និងភាពជាម្ចាស់ប្រចាំក្រុម។ មនុស្សវ័យក្មេងនឹងគោរពហើយមានអារម្មណ៍ថាខ្លួនត្រូវបានលើកទឹកចិត្ត។

សំបុត្រប្រហែលជាត្រូវការសកម្មភាពបន្តតាមក្រោយ ដោយការទាក់ទងតាមទូរស័ព្ទទៅកាន់មនុស្សដែលពាក់ព័ន្ធនេះគឺជាការពិត ប្រសិនបើអ្នកសរសេរទៅកាន់អ្នកនយោបាយ អ្នកល្បីល្បាញ ឬ អ្នកដឹកនាំនៅជុំវិញ។ ចូរប្រាប់ក្រុមកុំភ័យដោយសារមុខដំណែងរបស់មនុស្សដែលពួកគេកំពុងទាក់ទង។ មូលហេតុរបស់ពួកគេគឺជាបុព្វហេតុយុត្តិធម៌គ្មានការខូចខាតអ្វីក្នុងការគួរសមតាមទូរស័ព្ទ បន្ទាប់ពីផ្ញើសំបុត្រសំដែងការគួរសមរួច។ គេគួរតែអនុញ្ញាតមួយសប្តាហ៍ (អាស្រ័យលើទំនាក់ទំនងប្រព័ន្ធគមនាគមន៍នៅក្នុងប្រទេសដែលទាក់ទង) មុនពេលធ្វើការទំនាក់ទំនងផ្សេងៗតាមរយៈទូរស័ព្ទ។ លើកទឹកចិត្តក្រុមឱ្យតស៊ូ និង ស្វាហាប់ ប៉ុន្តែជានិច្ចកាលគឺទន់ភ្លន់គួរសមក្នុងការនិយាយទៅកាន់អ្នកណាក៏ដោយនៅតាមទូរស័ព្ទ។ សំបុត្រដែលពួកគេផ្ញើទៅចង់បានចម្លើយ ប្រសិនបើគ្មានការឆ្លើយតបទូរស័ព្ទប្រាប់ពីបំណង ដើម្បីទាក់ទាញការឆ្លើយតប។

ប្រសិនបើធនធានសម្ភារមិនអាចឈានដល់ការហៅទូរស័ព្ទលើកទឹកចិត្ត ក្រុមឱ្យសរសេរសំបុត្រខ្លី ហើយមានការគួរសមដើម្បីរំឭកទៅកាន់ បុគ្គលដែលទាក់ទងហើយដែលមិនបានឆ្ងើយតប។ប្រហែលជាមានមនុស្សខ្លះមិនឆ្លើយតបរហូត។ ក្នុងករណីនេះកុំចំណាយពេលវេលា និងធនធានក្នុងការទាក់ទងបន្តទៀត។ ចូរផ្តោតទៅលើអ្នកផ្សេងទៀតគឺអ្នកដែលបង្ហាញខ្លួនគេយ៉ាងទូលាយ ហើយមានការអើពើ។ ព្រោះតែការងាររបស់ក្រុមទទួលបាននូវគម្រោងខ្លះ ក្នុងសហគមន៍វាជាការប្រសើរដែលតំណាងសហគមន៍នឹងទាក់ទងទៅក្រុមដើម្បីសួរចង់ដឹងថែមទៀត។ នេះគឺជាសញ្ញាពិតមួយនៃជ័យជំនះក្នុងការលើកកម្ពស់ចំណេះដឹង និងទិដ្ឋភាពបញ្ចូលគម្រោងនេះទៅក្នុងសហគមន៍។

ម៉្យាងទៀត សំបុត្រដែលបានផ្ញើរួចហើយ អ្នកគួរតែប្រមូលផ្តោតទៅលើប្រភេទនៃការសម្ភាសន៍ តើសំណួរអ្វីខ្លះដែលគេចង់សួរ? អ្នកដែលត្រូវគេសម្ភាសន៍អាចស្នើសុំពិតទុកជាមុននូវសំណួរដែលអាចគេសួរ។ អ្នកគួរតែយល់ព្រមបញ្ហានេះ។ ដោយហេតុថាគោលបំណងគឺមិនរុញពួកគេឱ្យស្ថិតក្នុងភាពទាល់ច្រកនោះទេ។ ការមានសំណួរជាមុននឹងជួយអ្នកសម្ភាសន៍រៀបចំសម្រាប់សម្ភាសន៍ និងប្រាកដជាគេអាចឆ្លើយសំណួរបានយ៉ាងសំខាន់ដូចដែលអាចធ្វើបាន។ មនុស្សគ្រប់គ្នាមិនមែនសុទ្ធតែអាចឆ្លើយនូវសំណួរបានយ៉ាងស្រួលអំពីបញ្ហាពលកម្មកុមារឡើយ ឧទាហរណ៍ ប្រសិនក្រុមត្រូវទៅសម្ភាសន៍អ្នកគ្រប់គ្រងហាងម្នាក់អំពីទំនិញធ្វើតាមរយៈពលកម្មកុមារ។ អ្នកគ្រប់គ្រងហាងនឹងចង់ពិនិត្យមើលនូវគោលនយោបាយរបស់ក្រុមហ៊ុនអំពីរឿងនេះ ។

ដូច្នេះដំណាក់ការបន្ទាប់មកទៀតគឺទាក់ទងនឹងការធ្វើតារាងនៃសំណួរមូលដ្ឋានចូរត្រឡប់ទៅពិភាក្សាអំពីផ្នែកដ៏សមស្របនៃម៉ូឌុលនេះអំពីលំហាត់ស្ទាបស្ទង់មតិ។ គោលការណ៍ដូចគ្នាដែលអាចអនុវត្តបានក្នុងការបង្កើតតារាងសំនួរសម្រាប់សម្ភាសន៍។ ម្យ៉ាងវិញទៀតតារាងមិនគួរវែងពេកទេ ហើយខាតកម្លាំងសម្រាប់ការសម្ភាសន៍ប្រភេទនេះ មានមនុស្សម្នាក់នឹងត្រូវសរសេរកត់ត្រានូវចំនុចសំខាន់ ឬថតលំហាត់ ហើយអ្នកដែលត្រូវគេសម្ភាសន៍ពិតជាមនុស្សដែលរវល់និងមានពេលវេលាកំណត់។

ប្រសិនបើមានការសម្ភាសន៍លើសពីមួយក្រុម បំបែកក្រុមធំឱ្យទៅជាក្រុមតូចៗ ហើយប្រគល់ការងារឱ្យពួកគេម្នាក់ៗរៀបចំសំណួរសម្រាប់ការសម្ភាសន៍នេះ។ ពួកគេគួរតែសម្រេចចិត្តជ្រើសរើសរប្បៀបសួរផងដែរ តើសមាជិកក្រុមម្នាក់សួរមួយសំណួរឬ? ត្រូវឱ្យមនុស្សម្នាក់ជាអ្នករ៉ាប់រងការសួរសំនួរ ហើយអ្នកដទៃទៀតត្រូវទទួលបន្ទុកខាងកត់ត្រាចម្លើយ។ តើការសម្ភាសន៍ត្រូវថតចូលកាសែតម៉ាញ៉ូ ឬកាសែតវីដេអូឬទេ? តើអ្នកណាទទួលបន្ទុកលើការងារនេះ? តើនឹងសម្ភាសន៍នៅកន្លែងណា នៅក្នុងបន្ទប់របស់ក្រុម នៅការិយាល័យផ្ទាល់ខ្លួនរបស់អ្នកដែលទាក់ទងឬកន្លែងផ្សេងទៀត? តើមានការផ្តល់ជាភេសជ្ជៈបន្ទាប់ពីការសម្ភាសន៍ចប់ឬទេ? ជាការគួរសមទូទៅត្រូវជូនភេសជ្ជៈ ឬភេសជ្ជៈរសជាតិស្រាលដល់បុគ្គលនោះទោះនៅមុនពេលសម្ភាសន៍ ពេលកំពុង សម្ភាសន៍ ក្រោយពេលសម្ភាសន៍ក៏បាន។

រាល់ការរៀបចំទាំងនេះត្រូវលាតត្រដាងពិភាក្សានិងរៀបចំសកម្មភាពអនុវត្ត។ ប្រសិនបើការសម្ភាសន៍បានរៀបចំត្រឹមត្រូវ អ្នកដែលត្រូវគេសម្ភាសន៍នឹងធ្វើការកត់សម្គាល់ជាពិសេស ប្រសិនបើពួកគេជាអ្នកនយោបាយដែលមានបទពិសោធន៍អ្នកដឹកនាំជំនួញមន្ត្រីសហជីពពាណិជ្ជកម្ម ដែលឆ្លងកាត់លំហាត់នេះជាញឹកញាប់ផងនោះវានឹងផ្តល់នូវការចាប់អារម្មណ៍ដ៏យូរអង្វែង ហើយកែលំអនូវស្ថានភាពរបស់ក្រុមនៅក្នុងការយល់ឃើញរបស់ ពួកគេទាំងអស់នេះគឺទាក់ទងនឹងការកសាងនូវសម្ព័ន្ធភាពនិងទំនាក់ទំនងសហគមន៍។ ក្រុមប្រហែលជាត្រូវការទាក់ទងមនុស្សនេះម្តងទៀតនៅតំណាក់ការក្រោយៗទៀតនៃគម្រោង ដូច្នេះវាមានសារៈសំខាន់ក្នុងការផ្តល់នូវអារម្មណ៍ល្អដល់បុគ្គលដែលត្រូវគេសម្ភាសន៍ ។

លើកទឹកចិត្តក្រុមឱ្យគិតពីរបៀបអ្នកសម្ភាសន៍អាចឆ្លើយតបមកវិញ ហើយរៀបចំតាមលំដាប់សំណួរសម្រាប់អ្វីដែលកើតឡើងដោយឥតព្រាងទុក។ លើសពីនេះទៅទៀតឱ្យក្រុមហ៊ឹកហាត់ការសម្ភាសន៍ជាមួយគ្នាទៅវិញទៅមក។ សមាជិកក្រុមផ្សេងទៀតគួរតែដើរតួជាអ្នកស្តាប់ និងផ្តល់ដំបូន្មានទៅកាន់អ្នកសម្ភាសន៍គេ។ គេគួរតែផ្លាស់ប្តូរវេណគ្នាដើម្បីដើរតួជាអ្នកសម្ភាសន៍គេនិងអ្នកដែលត្រូវគេសម្ភាសន៍ហើយនឹងចាប់ផ្តើមមានអារម្មណ៍ល្អជាមួយដំណើរការនេះ។ ប្រសិនបើថតវីដេអូបានវាផ្តល់ផលប្រយោជន៍ក្នុងការបញ្ចាំងសាកល្បង និង ពិភាក្សាជាមួយពួកគេក្នុងក្រុមធំ។ បន្ទាប់មកអ្នករាល់គ្នាមានឱកាសចូលរួមក្នុងដំណើរការនេះ។ ប្រសិនបើប្រដាប់ថតវីដេអូមិនអាចរកបានចូរគិតដល់ការរៀបចំមេរៀនដើរតួមួយចំនួនតូចសម្រាប់ក្រុមធំដូច្នេះអ្នកគ្រប់គ្នាបានមើលឃើញការសម្ភាសន៍ ហើយអាចផ្តល់ដំបូន្មាន។ វាជាផ្នែកមួយសំខាន់ក្នុងក្រុមសកម្មដែលមានអារម្មណ៍ល្អនៅក្នុងក្រុមចំពោះចំនុចដែលគេអាចសើចចំអកឱ្យគ្នាទៅវិញទៅមក និងខ្លួនឯងបាន។ រាល់ការរៀបចំនេះនឹងបម្រើឱ្យយុវវ័យនៅក្នុងការអភិវឌ្ឍបុគ្គលិកលក្ខណៈសង្គមជាតិបានយ៉ាងល្អប្រសើរ។ នៅពេលឱកាសសម្រាប់សម្ភាសន៍បានមកដល់ ត្រូវឱ្យដឹងច្បាស់ថាក្រុមដែលមានការពាក់ព័ន្ធបានធ្វើការរៀបចំរាក់ទាក់ស្វាគមន៍ចំពោះបុគ្គលនោះយ៉ាងសមរម្យ និងជូនទៅកាន់កន្លែងសម្ភាសន៍។ អ្នកគួរតែបង្ហាញខ្លួនទទួលអ្នកសម្ភាសន៍ផងដែរ និងផ្តល់ព័ត៌មានដែលអាចផ្តល់បានអំពីគម្រោង និងសកម្មភាពដើម្បីកំនត់ថ្ងៃសម្ភាសន៍។ ទោះជាយ៉ាងណាក៏ដោយត្រូវផ្តល់ឱ្យសមាជិកក្រុមនិយាយឱ្យបានច្រើនដូចដែលអាចធ្វើទៅបាន

នេះជាដំណើរការសិក្សាមួយយ៉ាងសំខាន់សម្រាប់ពួកគេនៅក្នុងជំនាញផ្នែកទំនាក់ទំនង និងបំណិនសង្គម។ អ្នកគួរតែនៅជាប់ជាមួយក្រុមក្នុងកំឡុងពេលសម្ភាសន៍ និងត្រៀមខ្លួនផ្តល់ការគាំទ្រ ប្រសិនបើការសម្ភាសន៍មានភាពរអាក់រអួលឬក្តៅៗ មានអារម្មណ៍ភ័យខ្លាច។ ប្រសិនបើអ្នកមានសំណាង អ្នកដែលគេសម្ភាន៍នឹងយល់ពីការលំបាកដែលក្តៅៗ ត្រូវប្រឈមមុខក្នុងការធ្វើសម្ភាសន៍បែបនេះ ហើយនិងជួយបំពេញចន្លោះខ្វះខាតផ្សេងៗ និងលើកទឹកចិត្តដល់ក្រុម។

នៅចុងបញ្ចប់នៃការសម្ភាសន៍គួរផ្តល់ភេសជ្ជៈ និងជជែកគ្នាលេងជាមួយអ្នកដែលត្រូវគេសម្ភាសន៍ក្រុមគួរតែដឹងឱ្យច្បាស់ថាបុគ្គលដែលត្រូវគេសម្ភាសន៍បានទទួលការថ្លែងអំណរគុណមុនពេលបែកគ្នា ។ ជាការពិតប្រសិនបើការសម្ភាសន៍នេះត្រូវធ្វើក្នុងការិយាល័យ ទីកន្លែងជំនួញ ឬនៅគេហដ្ឋានរបស់អ្នកដែលត្រូវគេសម្ភាន៍នោះ ត្រូវបុគ្គលនោះជាអ្នកទទួលស្វាគមន៍ទៅវិញ។ នៅក្នុងករណីនេះ អ្នកគួរតែរួមដំណើរជាមួយក្រុមជានិច្ច។

វគ្គសួរសំណួរក្រោយពេលការធ្វើសម្ភាសន៍ត្រូវបានលើកយកមកពិភាក្សានៅក្នុងផ្នែកចុងបញ្ចប់នៃមេរៀន។ ទោះជាយ៉ាងណាក៏ដោយ ចូរបញ្ជាក់ឱ្យក្រុមបានយល់ថាការសម្ភាសន៍គឺជាលំហាត់ដែលបង្កើតនូវទំនាក់ទំនងសហគមន៍ ហេតុដូច្នេះហើយពួកគេគួរតែសំដែងនូវអំណរគុណដល់បុគ្គលដែលបានទទួលនូវការសម្ភាសន៍។

សកម្មភាពបន្ត

- ត្រូវធានាថាក្រុមនីមួយៗដែលធ្វើសម្ភាសន៍ក៏បានរៀបចំ និងផ្ញើរសំបុត្រថ្លែងអំណរគុណទៅកាន់បុគ្គលដែលទាក់ទងក្នុងការសម្ភាសន៍នេះឱ្យបានឆាប់បន្ទាប់ពីសកម្មភាពត្រូវបញ្ចប់ ។
- ត្រូវបញ្ជាក់ឱ្យច្បាស់ថាបុគ្គលគ្រប់ៗគ្នាបានចូលរួមនៅក្នុងគ្រប់វគ្គនៃម៉ូឌុលនេះ វាពុំមានភាពស្មុគស្មាញពិបាកយល់សម្រាប់អ្នករាល់គ្នាដែលមានតួនាទីក្នុងការរៀបចំដឹកនាំ និងវិភាគការសង្កេតទេ ប្រសិនបើកិច្ចសម្ភាសន៍ទុកដោយឡែកសម្រាប់ក្រុមតូចៗ នោះវារិតតែងាយស្រួលទៅទៀតដើម្បីធានាថាមនុស្សម្នាក់ៗមានតួនាទីនៅក្នុងការងារនេះ ។

អ្វីដែលត្រូវធ្វើ និងមិនត្រូវធ្វើ

- ត្រូវធ្វើការប្រើប្រាស់ប្រដាប់ថតវីដេអូ ឬកុំព្យូទ័រប្រសិនជាអាចរកបាន ។
- ត្រូវបញ្ជាក់ឱ្យច្បាស់ថា បុគ្គលគ្រប់គ្នាបានចូលរួមនៅក្នុងគ្រប់វគ្គនៃម៉ូឌុលនេះ។ ពុំមានភាពស្មុគស្មាញពិបាកយល់សម្រាប់អ្នករាល់គ្នាដែលមានតួនាទីក្នុងការរៀបចំដឹកនាំ និងវិភាគការសង្កេតទេ ។



- មិនចាំបាច់អនុវត្តលំហាត់ទាំងអស់នៅក្នុងម៉ូឌុលនេះទេ ដោយផ្អែកទៅលើពេលវេលាធនធាន និងការកម្រិតផ្សេងៗទៀតអ្នកប្រហែលជាចង់អនុវត្តលំហាត់តែមួយគត់នៅក្នុងលំហាត់ទាំងនេះ ចូរជ្រើសរើសលំហាត់ណាមួយដែលស័ក្តិសមបំផុតទៅនឹងតម្រូវការ និងកាលៈទេសៈរបស់ក្រុម ។
- ចេះកំប្លែងជាមួយក្រុម ដើម្បីជួយឱ្យឆាប់យល់មេរៀនជាពិសេសប្រសិនបើអ្នកប្រើប្រដាប់ថតវីដេអូ ឬសម្តែងតួក្នុងលំហាត់ ។
- ត្រូវប្រាកដថាការស្ងង់មតិ និងការសម្ភាសន៍ទាំងឡាយត្រូវបានពិភាក្សាយ៉ាងពេញលេញ និងរៀបចំយ៉ាងសមស្រប ។
- ត្រូវឱ្យប្រាកដថាបញ្ជីសំណួរស្ងង់មតិ និងសំណួរសម្ភាសន៍មិនវែងពេកហើយមិនពិស្តារពេក ។
- ធ្វើឱ្យប្រាកដថា ការស្ងង់មតិគឺបានវិភាគនិងមានសកម្មភាពបន្តហើយការសម្ភាសន៍មានសកម្មភាពបន្តដ៏សមស្របដែរ ។
- ចូរលើកទឹកចិត្តក្រុមឱ្យធ្វើលិខិតថ្លែងអំណគុណទៅកាន់បុគ្គលដែលបានចូលរួមក្នុងលំហាត់នេះ ។ បញ្ជាក់បន្ថែមទៅលើឥទ្ធិពលនៃការទំនាក់ទំនងក្នុងសហគមន៍ល្អ កុំជំរុញឱ្យក្មេងណាមួយធ្លាក់ក្នុងស្ថានភាពបាត់បង់នូវជំនឿទុក

ចិត្តលើខ្លួនឯង ជាពិសេសប្រសិនបើពួកគេមិនស័ក្តិសម ក្នុងការធ្វើសម្ភាសន៍។ សមាជិកនីមួយៗនៃក្រុម គួរតែស្វែងរកតួនាទីមួយក្នុងលំហាត់ទាំងនេះ ទោះបីជាគេមិនចូលរួមក្នុងការសម្ភាសន៍ដោយផ្ទាល់ក៏ដោយ។ លោកអ្នកគួរគាំទ្រដំណើរការនេះ ហើយមានជំនឿជឿជាក់ថាក្មេងទាំងអស់នោះដើរតួយ៉ាងងាយ ដោយមិនមានការបារម្ភ ។

- ចូរប្រាកដថាសមាជិកទាំងអស់នៃក្រុមបានចូលរួមក្នុងការសរសេរសំបុត្រដែលអាចជួយក្នុងការអភិវឌ្ឍបុគ្គលិកលក្ខណៈការប៉ុនប្រសប់ខាងទំនាក់ទំនងនិងបំណិនក្នុងសង្គមរស់នៅមិនត្រូវមានការប្រកួតប្រជែងក្នុងការធ្វើលំហាត់។
- ត្រូវឱ្យច្បាស់ថា លោកអ្នកបានអានទូវការដកស្រង់ដែលយកចេញពីគ្រប់លំហាត់មិនមែនត្រឹមតែអានទូវការស្រង់ដែលអ្នកគិតថាវាល្អជាងគេហើយពាក់ព័ន្ធច្រើននោះទេ។ ចំនួននៃការងារនិងទស្សនៈរបស់មនុស្សគ្រប់គ្នាព្រមទាំងរូបអ្នកត្រូវបានគេមើលឃើញថាយុត្តិធម៌ និងមិនមានការរិះគន់ ។

ការពិភាក្សាបញ្ចប់

បង្រៀនមួយពេល

នៅពេលដែលលំហាត់ស្ងង់មតិ ឬលំហាត់សម្ភានត្រូវបញ្ចប់ចូរប្រមូលផ្តុំក្រុមនៅក្នុងបន្ទប់ប្រជុំធម្មតា ឬបន្ទប់រៀន ហើយធានាឱ្យច្បាស់ថាមានបរិយាកាសសប្បាយរីករាយនិងធូរស្រាលក្រៃលែង។ ចូររាប់បញ្ចូលទាំងមនុស្សដែលធ្លាប់គាំទ្រពីខាងក្រៅផង។ ត្រូវមានសម្ភារដែលបានមកពីលំហាត់ដាក់នៅចំពោះមុខលោកអ្នកដូចជា : របាយការណ៍ ស្ងង់មតិ របាយការណ៍សម្ភាសន៍ និង ឯកសារវីដេអូ។

ចូរនិយាយអំពីដំណើរការដែលក្រុមបានឆ្លងកាត់ និងលើកទឹកចិត្តជំរុញឱ្យមានការពិភាក្សាទូទៅស្តីអំពីទិដ្ឋភាពនិមួយៗនៃលំហាត់ ដែលចាប់ផ្តើមពីការរៀបចំទៅដល់ការធ្វើពង្រាងការធ្វើសកម្មភាព និងបន្ទាប់មកទៀតគឺការបន្តសកម្មភាពដែលមានជាលំដាប់។ ស្វែងយល់អំពីអ្វីដែលគេចូលចិត្តជាងគេបំផុត និងកន្លែងដែលគេពុំសូវចូលចិត្ត។ ចូរឱ្យគេសម្តែងនូវមតិ និងអារម្មណ៍ដោយសេរី និងជាចំហនូវអ្វីៗដែលទាក់ទងបញ្ហានេះ។ ការដែលផ្តល់សេរីភាពដល់ពួកគេឱ្យបានជជែកគ្នា និងសម្តែងមតិយោបល់អំពីគម្រោងនេះ ក្នុងពេលដែលដំណើរការកំពុងបោះជំហានទៅមុខនោះគឺវាល្អមគ្រប់

គ្រាន់សម្រាប់បណ្តុះនូវភាពជឿជាក់ និងបង្កើននូវចំណងទាក់ទងនៅក្នុងក្រុមបន្ថែមទៀត។

ប្រសិនបើអ្នកមានឯកសារវីដេអូនៃការដើរតួសម្ភាសន៍ ឬការសម្ភាសន៍ដោយផ្ទាល់នេះគឺជាឱកាសសម្រាប់ចាក់ឱ្យក្រុមទាំងមូលបានមើលឃើញឡើងវិញអ្នកមិនទាន់បានធ្វើការងារដែលចាត់ថាជាផ្នែកនៃលំហាត់បណ្តុះបណ្តាល វាបម្រើនូវគោលបំណងនៃការដាក់ក្រុមក្នុងស្ថានភាពធូរស្រាលអារម្មណ៍នៅពេលដែលគេសើចចំអន់ខ្លួនឯង និងមិត្តភ័ក្តិទៅវិញទៅមក។ ហើយថែមទាំងមានប្រភេទចិត្តសាស្ត្រនៅពេលដែលក្រុមស្តាប់ចម្លើយសម្រាប់ឆ្លើយសំណួរផង។ ចូរនិយាយអំពីចម្លើយដែលផ្តល់ក្នុងការសម្ភាសន៍។ ចូរសួរទៅកាន់ក្រុមក្រែងលោពួកគេមានការភ្ញាក់ផ្អើលខកចិត្ត ឬត្រូវបានលើកទឹកចិត្តដោយសារចម្លើយនោះ។ តើគេគ្រោងនឹងបន្តទៅលើចម្លើយមួយចំនួនដោយរបៀបណា?

តើពួកគេមើលឃើញឥទ្ធិពលនៃការទាក់ទាញយកការគាំទ្រធំជាងគេពីបុគ្គលដែលទាក់ទងឬទេ? ដោយរបៀបណា ? ជាមួយគ្នានេះលោកអ្នកធ្វើឱ្យក្រុមមានសកម្មភាពយឺតៗឆ្ពោះទៅកន្លែងយុទ្ធនាការ។

ក្រឡេកមកលទ្ធផលនៃការស្ទង់មតិ និងរបាយការណ៍ដែលយើងបានសរសេររួចហើយ តើក្រុមមានប្រតិកម្មអ្វីខ្លះទៅលើបញ្ហាទាំងនេះ សូមឱ្យពួកគេបង្ហាញពីអារម្មណ៍ផ្ទាល់ខ្លួនរបស់ពួកគេទៅនឹងលទ្ធផល។ សុំឱ្យពួកគេបន្តសកម្មភាពតទៅទៀត ប្រសិនបើគេពេញចិត្ត តើពួកគេបានឃើញលទ្ធផលនៃសកម្មភាពបន្តបន្ទាប់ទៅលើការស្ទាបស្ទង់មតិដែរឬទេ? ចុះប្រព័ន្ធផ្សាយវិញមានអ្វីខ្លះ?

លំហាត់គួរតែបង្កើនបំណិនដល់កុមារ ក្នុងការដឹកនាំស្រាវជ្រាវសកម្មភាពទំនាក់ទំនងជាមួយអ្នកផ្សេងទៀត និងសិក្សាពីរបៀបវិភាគ និងបង្ហាញពត៌មាន។ វាថែមទាំងជួយក្មេងៗឱ្យបានវិភាគ និងបង្ហាញពត៌មាន។ វាថែមទាំងជួយក្មេងៗឱ្យបានដឹងថាការយល់ដឹងអំពីបញ្ហាពលកម្មកុមារគឺ នៅមានចំនួនតិចតួចស្តួចស្តើងយ៉ាងណានៅក្នុងសង្គមមនុស្សដ៏ធំទូលាយនេះ។ កត្តានេះវាប្រហែលជាជំរុញការប្រឹងប្រែងរបស់ពួកគេឱ្យរីតតែសកម្មឡើង ក្នុងការបន្តចាត់វិធានការគាំទ្រយុទ្ធនាការលប់បំបាត់ពលកម្មកុមារ ។វាថែមទាំងផ្តល់មូលដ្ឋានគ្រឹះដ៏ធំ សម្រាប់ក្រុមដែលគេអាចលៃលក់ដោះស្រាយរាល់ម៉ូឌុលផ្សេងៗទៀត។



ការវាយតម្លៃ និងសកម្មភាពបន្ត

ការកំណត់ចង្អុលបង្ហាញដែលអាចវាស់វែងបានសម្រាប់ស្បៀវភៅម៉ូឌុលនេះគឺមានច្រើនណាស់គឺលទ្ធភាពជាក់លាក់រួមមាន ÷



- ការរៀបចំកម្រងសំណួរសម្រាប់ធ្វើការអង្កេត
- ការអនុវត្តនូវការអង្កេត
- ការប្រមូល និងការវិភាគបញ្ជីសំណួរស្ទង់មតិ
- ការរៀបចំរបាយការណ៍ស្ទង់មតិ និងការផ្សព្វផ្សាយដ៏មានសក្តានុភាព ។
- ការត្រួតដណ្តប់របាយការណ៍អង្កេតរបស់ប្រព័ន្ធផ្សព្វផ្សាយ
- ការប្រមូលផ្តុំតារាងរបស់បេក្ខជនធ្វើសម្ភាសន៍និងការទទួលសេចក្តីអញ្ជើញ ។
- ការដឹកនាំសម្ភាសន៍ទាំងឡាយ និងការបង្កើនទំនាក់ទំនងជាមួយអ្នកដែលត្រូវគេសម្ភាសន៍ ។
- សកម្មភាពបន្តពីសម្ភាសន៍ និងការសម្របសម្រួលបញ្ជូលក្នុងសហគមន៍ព្រមទាំងការលើកកម្ពស់នូវការយល់ដឹង ។

ជាការពិតនៅមានការចង្អុលបង្ហាញដទៃទៀតផ្សេងទៀត ប៉ុន្តែបើការបង្ហាញខាងលើលេចឡើង ក្រុមនោះនឹងធ្វើការបានល្អ ហើយលោកអ្នកគួរតែប្រាប់ពួកគេដូច្នេះដែរ។ លំហាត់ក្នុងម៉ូឌុលនេះពិតជាគួរឱ្យចាប់អារម្មណ៍ និងមានការរីករាយយ៉ាងខ្លាំងសម្រាប់ក្មេងៗ ។ វាក៏អាចមានប្រសិទ្ធភាពខ្ពស់នៅក្នុងដំណើរការអប់រំទៀតផង។ នៅម៉ូឌុលនេះវាអាចមានឥទ្ធិពលដ៏សំខាន់ទៅលើទំនាក់ទំនង និងការបិនប្រសប់រស់នៅក្នុងសង្គមរបស់ពួកគេហើយនិង ការអភិវឌ្ឍន៍នូវបុគ្គលិកលក្ខណៈផ្ទាល់របស់ពួកគេជារួម។ នៅពេលដំពូកនេះត្រូវបានបញ្ចប់ ដោយសេចក្តីពេញចិត្តរបស់ (លោក) អ្នកនោះ អ្នកអាចបន្តទៅម៉ូឌុលមួយផ្សេងទៀត។ លទ្ធភាពមួយដែលអាចទៅបានគឺជាម៉ូឌុលបញ្ជូលក្នុងសហគមន៍ ប៉ុន្តែលោកអ្នកប្រហែលជាចង់បន្តទៅរកផ្នែកឬវិស័យថ្មីៗទៀតដូចជារឿងល្ខោន និងសិល្បៈជាដើម ។

ខ្លឹមសម្ព័ន្ធ ១

បច្ចេកទេសសម្ភាសន៍ ឬអង្កេតមួយទល់មួយ

ប្រសិនបើការស្ទាបស្ទង់មតិ ពឹងផ្អែកទៅលើរបៀបសម្ភាសន៍មួយទល់មួយក្រុមគួរតែទទួលការបណ្តុះបណ្តាលនូវរបៀបដឹកនាំសម្ភាសន៍។ កត្តានេះនឹងជួយដល់ការសម្ភាសន៍នៅក្នុងម៉ូឌុលនេះ។ ប្រសិនបើការស្ទង់មតិបានជោគជ័យ ការយកចិត្តទុកដាក់ គួរតែផ្តោតលើគុណភាព ហើយជាលទ្ធភាពវាត្រូវអាស្រ័យទៅលើលទ្ធភាពរបស់អ្នកសម្ភាសន៍ ដើម្បីធ្វើឱ្យប្រធានបទមានភាពងាយស្រួលច្បាស់លាស់និងសង្ខេបយកតែចំណុចសំខាន់នៅក្នុងការសួរសំណួរ។

ជាការពិតលក្ខណៈនៃការបណ្តុះបណ្តាលគឺអាស្រ័យទៅលើក្រុមមុខសញ្ញាដែលត្រូវគេអង្កេត។ ឧទាហរណ៍ : តើការសម្ភាសន៍រៀបចំលើផ្លូវសាធារណៈ និងផ្តោតទៅលើសាធារណជនឬ ? ឬមួយត្រូវគេធ្វើនៅជុំវិញបរិវេណក្នុងហាងឬកន្លែងធ្វើការ ហើយផ្តោតការយកចិត្តទុកដាក់ទៅលើកម្មករឬ? ឬធ្វើនៅក្នុងសាលាហើយផ្តោតទៅ លើក្រុមមនុស្សដែលមានវ័យ និងឋានៈស្មើគ្នា? ក្មេងៗនឹងមានប្រតិកម្មផ្សេងៗគ្នា គឺថាបើគេកំពុងសម្ភាសន៍មនុស្សទៅលើផ្លូវនោះវាផ្សេងគ្នាកាលបើគេកំពុងសម្ភាសន៍មិត្តភក្តិគេនៅក្នុងថ្នាក់រៀនមួយផ្សេងទៀត ។

ទោះជាយ៉ាងណាក៏ដោយ គោលការណ៍នៅតែដូចគ្នា ÷

- បង្ហាញឱ្យគេស្គាល់ខ្លួនអ្នក និងជនដែលត្រូវជំនួសមុខអោយហើយសួរសំណួរទៅកាន់មនុស្សដែលអ្នកត្រូវសម្ភាសន៍ក្រែងលោគាត់សុខចិត្តឱ្យសម្ភាសន៍រួចរៀបរាប់ពីគោលបំណង និងគោលដៅនៃការអង្កេតឱ្យបានច្បាស់លាស់។
- ចូរបង្កភាពធូរស្រាល និងរីករាយដល់មនុស្សដែលត្រូវសួរ និងដល់ខ្លួនអ្នក
- ចាប់ផ្តើមសួរត្រង់ៗ ដោយសំណួរងាយៗ
- ជានិច្ចកាលត្រូវចេះគួរសម និងរួសរាយ
- សម្លឹងមើលមុខមនុស្សដែលអ្នកកំពុងសួរ
- កុំបង្ខំសួរ និយាយឱ្យច្បាស់ ហើយឱ្យប្រាកដថាអ្នកកត់ចំណុចសំខាន់នៃការឆ្លើយតប ។
- ប្រើម៉ាញ៉ៅប្រសិនបើការកត់ត្រាចម្លើយត្រូវចំណាយពេលយូរព្រោះថាមនុស្សយើងអាចនឹងបាត់បង់ការអត់ធ្មត់ ។
- ត្រូវដិតជាប់នឹងអក្សរ។ ចូរកុំបន្ថែមសំណួរឬកាត់ចោលសំណួរណាមួយ ប្រសិនបើសំណួរនោះមិនមានបង្កភាពមិនសមរម្យដែលគួរឱ្យធុញទ្រាន់ដល់ការសម្ភាសន៍។

- នៅពេលអ្នកសួរសំណួរចូរឱ្យឱកាសដល់មនុស្សដែលមកសម្ភាសន៍ ដើម្បីឱ្យពួកគាត់បានសួរសំណួរផ្ទាល់របស់គាត់វិញ ។ ចូរឆ្លើយសំណួរគាត់ដោយពីស្ពារ និងគួរសម ។
- ពេលសម្ភាសន៍ចប់ ត្រូវថ្លែងអំណរគុណដល់ពួកគាត់ដែលបានចំណាយពេលវេលា។ ប្រសិនបើមានទំនាក់ទំនង និងចូរប្រាប់គាត់ពេលណាដែលលទ្ធផលត្រូវចេញផ្សាយ និងកន្លែងដែលលទ្ធផលទាំងនេះត្រូវគេបង្ហាញឱ្យមើល ។

ឯបសម្ព័ន្ធ ២

ក្រិតក្រមជាមូលដ្ឋានៃការសរសេរសំបុត្រ

សមាជិកសភាអង់គ្លេសម្នាក់បាននិយាយថា : "ខ្ញុំជំនួសមុខឱ្យសមាជិកសភាតំណាងរាស្ត្រចំនួន ៤0000 នាក់។ ខ្ញុំមិនដែលឮអ្វីមួយពីពួកគេដែលមានគ្នាចំនួនប្រហែល ៣៥000 នាក់ទេ ។ ប្រសិនបើពួកគេម្នាក់ក្នុងចំណោមគ្នា ១0000 នាក់ ផ្សេងទៀតនិយាយមកកាន់ខ្ញុំ នោះខ្ញុំមានការចាប់អារម្មណ៍។ ប្រសិនបើអ្នក ៥0នាក់ សរសេរមកខ្ញុំខុសៗគ្នា នោះវាគឺជាបញ្ហាសំខាន់ ហើយខ្ញុំប្រាកដជាធ្វើការកត់សំគាល់។ ប្រសិនបើមនុស្ស ១00 នាក់ សរសេរមកកាន់ខ្ញុំអំពីប្រធានបទមួយនោះវាជាប្រភេទបញ្ហាដែលសម្រេចនូវការបោះឆ្នោត ហើយប្រសិនបើមនុស្សច្រើនជាងនេះសរសេរមកកាន់ខ្ញុំនោះខ្ញុំគិតថាវាប្រហែលជាប្រភេទនៃរឿងដែលបណ្តាលឱ្យមានបដិវត្ត "។

វាគឺពិតសម្រាប់គាត់ហើយ រឹតតែជាការពិតសម្រាប់មនុស្សដែលមិនសង្ឃឹមថានឹង ឮជាញឹកញាប់ពីសាធារណជនដូចជាអ្នកជំនួញ , អ្នកគ្រប់គ្រងផ្សារទំនើប , ពាណិជ្ជករ និងផ្នែករដ្ឋាភិបាលសហជីពពាណិជ្ជកម្ម សមាជិកក្រុមប្រឹក្សាក្រុង ម្ចាស់ហាង និងអ្នកមុខងារផ្សេងទៀតដែលមានតួនាទីជាអ្នកទទួលខុសត្រូវ ដូច្នេះចូរឆក់ឱកាសរួចចាប់ផ្តើមសរសេរតាមគោលការណ៍ជាមូលដ្ឋាន សំបុត្រគួរតែឱ្យខ្លីមានការគួរសម និងចំគោលដៅ អ្នកគួរតែសុំការឆ្លើយតបបញ្ចូលឈ្មោះ និងអាស័យដ្ឋានរបស់ក្រុមសម្រាប់គោលបំណងនេះ ។ គោលការណ៍សរសេរសំបុត្រផ្សេងទៀតរួមមាន ÷

- ជានិច្ចកាលត្រូវចារអាស័យដ្ឋាននៅខ្នងសំបុត្ររួចផ្ញើទៅទីកន្លែងធ្វើការ ឬពាណិជ្ជកម្មដែលមិនមែនផ្ទះរបស់បុគ្គលទេ ។
- កំណត់ឱ្យឃើញអ្នកសម្រេចចិត្ត និងសរសេរសំបុត្រទៅកាន់បុគ្គលទាំងនេះ វាមានសារៈប្រយោជន៍ក្នុងការស្រាវជ្រាវលើបញ្ហានេះ ។
- សរសេរទៅកាន់មនុស្សដោយដាក់ឈ្មោះប្រសិនបើអាចដាក់បាន ។ ប្រហែលជាត្រូវប្រើទូរស័ព្ទដើម្បី ស្វែងរកព័ត៌មាននេះដោយការគួរសម។
- គ្រឿងបំភ័ន្តមួយអាចទទួលបាននូវការចាប់អារម្មណ៍ពីសាធារណជនខុទាហរណ៍ : ប័ណ្ណប្រៃយសណីយ៍ដែលមានពណ៌ប្លែកៗ ប័ណ្ណប្រៃយសណីយ៍ដែលកាត់ចេញពីរូបភាពធំៗ ដូចជាល្បែងផ្គុំរូប ឬប័ណ្ណផ្ទាំងធំដែលបានចុះហត្ថលេខា ដោយមនុស្សចំនួន ២000 នាក់ ។
- ជានិច្ចកាលផ្ញើសំបុត្រអរគុណប្រសិនបើអ្នកបានទទួលការឆ្លើយតប ឬប្រតិកម្មចំពោះលិខិតដំបូង ។

សំបុត្រគំរូនៅក្នុងឧបសម្ព័ន្ធទី ៣ សុទ្ធតែមានគោលបំណងទាញយកព័ត៌មាន និងការចាប់អារម្មណ៍ ។ សំបុត្រគឺជាវត្ថុផ្ទាល់ខ្លួន ។ លិខិតទាំងនោះជាការបង្កើតថ្មីរបស់អ្នកដែលសរសេរវា ។ ដោយហេតុនេះយើងមិនគួរនឹងរារាំងនូវ គំនិតបង្កើតថ្មី និងការស្រមៃរបស់ក្មេងៗជុំវិញពិភពលោក ដែលប្រហែលជាកំពុងធ្វើការជាមួយជំពូកទាំងនេះ ។ ដូច្នេះហើយពួកយើងជំរុញណែនាំអ្នកអប់រំឱ្យប្រយ័ត្នក្នុងការប្រើប្រាស់គំរូសំបុត្រទាំងនេះ។ យើងសូមផ្តល់អនុសាសន៍ថាអ្នកមិនត្រូវចម្លងសំបុត្រនោះទាំងស្រុង ហើយចែកសំបុត្រឱ្យក្រុមផ្សេងៗឡើយ យកល្អអានសំបុត្រដោយខ្លួនឯងហើយចាត់ទុកសំបុត្រទាំងនោះថាជាឧបករណ៍ជួយធ្វើឱ្យការពិភាក្សាមានសកម្មភាពនៅក្នុងក្រុម ។

ពេលធ្វើការពង្រាងសំបុត្រជាមួយក្រុម ត្រូវចងចាំថាពួកគេត្រូវសរសេរឱ្យខ្លីហើយច្បាស់បើអាចធ្វើបាន។ ជាទូទៅព្យាយាមកុំសរសេរសំបុត្រលើសពីមួយទំព័រ ច្រើនបំផុតពីរទំព័រ។ ប្រសិនបើបន្តដល់ពីរទំព័រ ព្យាយាមបញ្ចប់នៅពាក់កណ្តាលទំព័រទីពីរ។ សំបុត្រវែងៗប្រហែលជាមិនត្រូវបានអានទេ ព្រោះថាពេលវេលាជារបស់សំខាន់ដែលកម្របានណាស់នៅពេលនេះអ្នកគួរតែឱ្យប្រាកដថាសំបុត្របានទាក់ទាញអារម្មណ៍អ្នកអានហើយធ្វើ ឱ្យពួកគេពេញចិត្តចង់អានលិខិតនោះរហូតដល់ទីបញ្ចប់ ។

ឧបសម្ព័ន្ធ ៣

លិខិតគំរូ

លិខិតស្នើសុំការជួយឧបត្ថម្ភពីអង្គការ

សូមគោរពជូន .....

ពួកយើងកំពុងសរសេរស្នើសុំជំនួយឧបត្ថម្ភរបស់លោកអ្នកចំពោះបញ្ហាលើបញ្ហានេះពីលោក ដែលយើងជឿថា វាទាក់ទងដល់ជនគ្រប់រូបនៅលើពិភពលោកយើងនេះដោយគ្មានការលើកលែង ។ ពួកយើងគឺជាថ្នាក់ឬឈ្មោះក្រុម និង ទីកន្លែង ហើយកំពុងតែធ្វើការលើការងារនេះដែលចូលរួមលើកកម្ពស់ចំណេះដឹងអំពីបទឧក្រិដ្ឋពលកម្មកុមារ និងកំពុងធ្វើការក្នុងយុទ្ធនាការជាអន្តរជាតិដើម្បីបញ្ឈប់ពលកម្មកុមារ ។ ពួកយើងមានការតក់ស្លុតដោយបានដឹងថាមានកុមារប្រហែលជា ២៤៥ លាននាក់ ដែលអាយុក្រោម ១៨ ឆ្នាំ កំពុងធ្វើពលកម្មទូទាំងពិភពលោក ។

ពួកយើងខ្ញុំមានកិត្តិយស ដោយបានបញ្ជូលនូវជំនួយរបស់អង្គការលោកក៏ដូចជាជំនួយរបស់លោកផ្ទាល់ទៅលើគម្រោងរបស់យើងខ្ញុំ និងបញ្ហានេះជាសាធារណៈ។ យើងដឹងពីរបៀបចូលរួមរបស់ (ឈ្មោះរបស់អង្គការ) ក្នុងបញ្ហា ដែលមានការខ្វល់ខ្វាយ និងពាក់ព័ន្ធដល់សង្គមរស់នៅដូចជាបញ្ហាពលកម្មកុមារជាដើម ។

ទិសដៅមួយក្នុងចំណោមទិសដៅទាំងអស់របស់ពួកយើង គឺចាប់យកបញ្ហានេះចេញមកក្រៅរួចបញ្ជូលបញ្ហានេះជាសាធារណៈហើយនៅក្នុងន័យនេះពួកយើងចង់សំណូមពរឱ្យលោកគាំទ្រគម្រោងរបស់ពួកយើងជាសាធារណៈ ។ ពួកយើងមានអារម្មណ៍ថាដោយមានការគាំទ្ររបស់លោកទាំងប្រព័ន្ធផ្សព្វផ្សាយ ទាំងរាជរដ្ឋា ភិបាលទាំងសហគមន៍របស់ពួកយើងនឹងស្តាប់ដោយយកចិត្តទុកដាក់នូវអ្វីដែលយើងត្រូវនិយាយ ហើយចាប់ផ្តើមគិតគូអំពីបញ្ហាពលកម្មកុមារដែលគួរឱ្យភ័យខ្លាចនិងត្រូវធ្វើអ្វីមួយដើម្បីបញ្ឈប់ពលកម្មកុមារជាស្ថាពរ ។ ប្រសិនបើពួកយើងធ្វើការរួមគ្នា ពួកយើងអាចធ្វើឱ្យមានការផ្លាស់ប្តូរបាន ។

គម្រោងរបស់ពួកយើងនឹងផ្សព្វផ្សាយព័ត៌មានទៅដល់មនុស្សទាំងឡាយ តាមរយៈការមើលឃើញ, អក្សរសិល្ប៍ ,ពីល្ខោន និងប្រព័ន្ធផ្សព្វផ្សាយ (ឧទាហរណ៍ ប្រសិនបើមានសកម្មភាពមួយនៅខាងមុខ) ។ ពួកយើងបានសម្តែងសិល្បៈដោយខ្លួនឯង សាច់រឿងស្តីអំពីពលកម្មកុមារ (កាលបរិច្ឆេតទីកន្លែង) ។ ពួកយើងមានការរំភើបចិត្តប្រសិនបើអ្នកអាចនៅទីនោះក្នុងនាមជាភ្ញៀវរបស់ពួកយើងនៅល្ងាចនោះ។ ពួកយើងចង់ធ្វើការងារបន្តិចបន្តួចឱ្យពិភពលោកនេះប្រសើរឡើងវិញភ្លឺថ្លាត្រចះត្រចង់ និងជាកន្លែងដែលមានសេចក្តីសុខ សុវត្ថិភាពសម្រាប់មនុស្សគ្រប់គ្នាជាពិសេសក្មេងៗដែលត្រូវបានរងការកេងប្រវ័ញ្ចលើពលកម្ម។ យើងយល់ថាលោកអ្នកនឹងចូលរួមសេចក្តីសង្ឃឹម និងក្តីស្រមៃរបស់ពួកយើង ទោះជាយ៉ាងណាក៏ដោយវាប្រាកដជាជំនួយមួយ ប្រសិនបើអ្នកទទួលនូវការអញ្ជើញរបស់ពួកយើង ដើម្បីគាំទ្រគម្រោងរបស់យើងខ្ញុំជាសាធារណៈ ។

សូមមេត្តាឆ្លើយតបឱ្យបានឆាប់រហ័សប្រសិនបើអ្នកអាចមានលទ្ធភាពព្រោះថាពេលវេលាមានតិចណាសម្រាប់អ្នកធ្វើពលកម្មរាប់លាននាក់ទូទាំងសកលលោកដែលជាកុមារ ។

សំបុត្រសរសេរទៅក្រុមហ៊ុនដើម្បីសុំការធានា

កំណត់សម្គាល់ : ក្នុងឧទាហរណ៍នេះក្រុមហ៊ុនគឺជាអ្នកផ្គត់ផ្គង់គ្រឿងបរិក្ខានិងសំភារៈការិយាល័យ ។

សូមគោរពជូន.....

ពួកយើងខ្ញុំកំពុងតែសរសេរសំណូមពរឱ្យលោកជួយគាំទ្រលើបញ្ហាមួយដែលយើងមានជំនឿថាមនុស្សលើពិភពលោកខ្វាយខ្វល់ពុំអាចគេចផុតបាន ។ ពួកយើងខ្ញុំគឺ (ថ្នាក់ ឬឈ្មោះក្រុមនិងទីកន្លែង) ហើយកំពុងតែធ្វើការនៅលើគម្រោងមួយដែលបានចូលរួមលើកកម្ពស់ចំណេះដឹងអំពីបញ្ហាឧក្រិដ្ឋកម្មទៅលើពលកម្មកុមារ និងកំពុងតែឃោសនាយុទ្ធនាការជាអន្តរជាតិដើម្បីបញ្ឈប់បញ្ហានេះ ។ ពួកយើងមានការតក់ស្លុតដែលបានដឹងថាក្មេងៗប្រហែល ២៤៥ លាន នាក់អាយុក្រោម ១៨ ឆ្នាំកំពុងតែធ្វើការទូទាំងពិភពលោកនេះ ។

ពួកយើងមានកិត្តិយស និងមោទនភាពដោយបានកត់ចូលនូវជំនួយពីក្រុមហ៊ុនរបស់លោកអ្នកដើម្បីគាំទ្រគម្រោងរបស់ពួកយើងខ្ញុំនិងផ្សព្វផ្សាយបញ្ហានេះជាសាធារណៈ ។ ទិសដៅមួយក្នុងចំណោមទិសដៅជាច្រើន គឺបង្កើតការទំនាក់ទំនងគ្នាទៅវិញទៅមកជាមួយនឹង (ឧទាហរណ៍) សាលារៀនមួយនៅក្នុង(ឈ្មោះប្រទេស) ដើម្បីផ្តល់ការជួយរបស់យើងដល់ក្មេងដែលទទួលសិទ្ធិបានតិចជាងពួកយើង ជាពិសេសនៅក្នុងប្រទេស ដែលពលកម្មកុមារត្រូវបានរីករាលដាលយ៉ាងធំ។ ពួកយើងខ្ញុំចង់លើកយកបញ្ហានេះដើម្បីផ្សព្វផ្សាយជាសាធារណៈ ហើយពួកយើងខ្ញុំចង់ធ្វើអ្វី គ្រប់បែបយ៉ាងដែលយើងអាចជួយបាន ។

យើងកំពុងតែសង្ឃឹមថានឹងបញ្ចូលនូវជំនួយរបស់សហគមន៍ផ្សេងៗនៅក្នុងប្រទេសរបស់យើងខ្ញុំ។ ប្រសិនបើពួកយើងធ្វើការរួមគ្នា ពួកយើងអាចធ្វើឱ្យមានភាពខុសប្លែកមួយ ។ ពួកយើងបានរៀបចំការអង្គាសប្រាក់ក្នុងពេលដែលកំពុងដំណើរការគម្រោងរបស់ពួកយើងហើយប្រមូលបានប្រាក់ចំនួន.....(ចំនួនទឹកប្រាក់ដែលប្រមូលបាន)។ ដែលយើងចង់ប្រើដើម្បីទិញសំភារៈការិយាល័យដាក់សាលា និងសំភារៈសម្រាប់សាលាដែលយើងកំពុងតែធានា (ឈ្មោះសាលា)។ យើងនឹងទាក់ទងសិស្សនៅទីនោះ ដើម្បីសួរពួកគេនូវអ្វីដែលគេចង់បានជាទីបំផុតដាក់ក្នុងថ្នាក់រៀនរបស់ពួកគេ ។ ពួកយើងខ្ញុំកំពុងសុំជំនួយរបស់អ្នកព្រោះពួកយើងខ្ញុំចង់ទិញសំភារៈដែលគេត្រូវការពីក្រុមហ៊ុនរបស់លោកអ្នកដោយហេតុថារបស់លោកសមរម្យពួក យើងអាចទិញសំភារៈបានច្រើនសម្រាប់ពួកគេ ។

ពួកយើងកំពុងតែសង្ឃឹមថាលោកអ្នកអាចជួយពួកយើងខ្ញុំ ហើយផ្ទៀវត្ថុទាំងនេះឱ្យពួកគេបានច្រើនតាមដែលអាចធ្វើបាន។ ប្រសិនបើពួកយើងខ្ញុំត្រូវចំណាយអស់ថវិការរបស់ពួកយើងខ្ញុំជាមួយនឹងក្រុមហ៊ុនរបស់លោក តើលោកអ្នកសុខចិត្តជួយយើងដោយបន្ថែមឱ្យកើនឡើងទ្វេរដងនូវចំនួនប្រាក់ដែលយើងបានចំណាយឬទេ?

យ៉ាងហោចណាស់ចែករំលែកអ្វីមួយថែមទៀតលើចំនួននោះបានឬទេ? នេះគឺដើម្បីបុព្វហេតុមួយដ៏ប្រសើរក្រៃលែង ។

-ក្មេង១ទាំងនេះខ្វះខាតនូវសំភារៈសិក្សាមូលដ្ឋាន ។

ពួកយើងខ្ញុំសូមជំរាបអស់លោកអំពីគម្រោងរបស់ពួកយើងថែមទៀត ។ ពួកយើងចង់ផ្តល់ព័ត៌មានដល់មនុស្សទាំងឡាយតាមរយៈសិល្បៈ ការសរសេរដោយច្នៃប្រឌិត, ល្ខោន និងប្រព័ន្ធផ្សព្វផ្សាយ, សមិទ្ធផលដែលសម្រេចបានដ៏ធំធេងរបស់យើងគឺ (ឧទាហរណ៍) ការសរសេរនិងការសំដែងរឿងល្ខោនស្តីពីពលកម្មកុមារ ។

ពួកយើងចង់ឱ្យពិភពលោកកាន់តែប្រសើរជាងនេះ ភ្លឺស្វាង និងជាកន្លែងសុវត្ថិភាពសម្រាប់មនុស្សគ្រប់គ្នា ជាពិសេសទៅលើកុមារដែលរងការកេងប្រវ័ញ្ចពលកម្ម ។ យើងដឹងថាលោកអ្នក និងចែករំលែកសេចក្តីសង្ឃឹម និងការស្រមើស្រមៃ។ ដូច្នេះហើយវាប្រាកដជាជំនួយមួយប្រសិនបើលោកអ្នកទទួលការអញ្ជើញដើម្បីគាំទ្រជាសាធារណៈនូវគម្រោងរបស់ពួកយើងខ្ញុំជាមួយនឹងសំភារៈសិក្សាសម្រាប់សិស្សសាលានៅក្នុងឈ្មោះ (ប្រទេស) ។ ឆ្លងកាត់ការអប់រំ ក្មេង១ទាំងនេះនឹងមានអនាគតភ្លឺស្វាង ហើយមិនបាច់ធ្វើការទាំងវ័យក្មេងបែបនេះឡើង ។

សូមមេត្តាឆ្លើយតបឱ្យបានឆាប់តាម ដែលលោកអ្នកធ្វើទៅបាន ព្រោះពេលវេលាខ្លីណាស់សម្រាប់កុមាររាប់លាននាក់ដែលកំពុងធ្វើពលកម្មហួសកម្លាំងជុំវិញពិភពលោក ។

សំបុត្រស្នើសុំសម្ភាសន៍ជាមួយក្រុមហ៊ុន

សូមគោរពជូន.....

ពួកយើងខ្ញុំកំពុងតែសរសេរសំបុត្រ សុំការជួយទំនុកបម្រុង និងគាំទ្រនៅលើបញ្ហាដែលពួកយើងខ្ញុំជឿថាមនុស្សគ្រប់រូបក្នុងពិភពលោកមានកង្វល់មិនអាចគេចផុតបាន ។ ពួកយើងខ្ញុំគឺ (ថ្នាក់ ឬឈ្មោះក្រុម និងទីកន្លែង) កំពុងធ្វើការនៅលើគម្រោងមួយដែលចូលរួមក្នុងការលើកកំពស់ការយល់ដឹងអំពីបទឧក្រិដ្ឋធ្ងន់ធ្ងរទៅលើពលកម្មកុមារ និងចូលរួមក្នុងយុទ្ធនាការអន្តរជាតិ ដើម្បីបញ្ឈប់បទឧក្រិដ្ឋនេះ យើងភ្ញាក់ផ្អើលតក់ស្លុតដោយបានដឹងថាកុមារប្រហែល ២៤៥ លាននាក់ក្រោមអាយុ ១៨ ឆ្នាំកំពុងធ្វើការទូទាំងពិភពលោក ។

ការងារដែលពួកយើងកំពុងតែធ្វើនេះនឹងជួយបង្កើននូវការប្រឹងប្រែងរបស់ពួកយើងចំពោះសហគមន៍ផ្សេងៗ ទាំងអស់នេះនឹងជួយអប់រំអ្នកដទៃទៀត ។ សហគមន៍សំខាន់មួយដែលពាក់ព័ន្ធទៅនឹងបញ្ហាពលកម្មកុមារ គឺសហគមន៍ ពាណិជ្ជកម្ម។ ពួកយើងខ្ញុំបានចាប់អារម្មណ៍ក្នុងការស្វែងយល់ពីវិធីជាច្រើន ដែលក្រុមហ៊ុនធ្វើការត្រួតពិនិត្យនូវនយោបាយ និងយុទ្ធសាស្ត្រក្នុងការទិញដើម្បីធានាថាទំនិញដែលគេទិញសម្រាប់លក់ម្តងទៀតនៅក្នុងឃ្លាំងរបស់ពួកគេត្រូវបានផលិតនិងបណ្តុះឡើងក្រោមលក្ខខ័ណ្ឌការងារសមស្របដែលត្រូវគោរពតាមចំណុចសំខាន់ស្តង់ដាពលកម្មអន្តរជាតិ ។ ពិចារណាទៅឃើញថាលោកអ្នកគឺជាក្រុមហ៊ុនដ៏សំខាន់

មួយក្នុងសហគមន៍មូលដ្ឋានរបស់យើងពួកយើងនឹងផ្តែងនូវអំណរគុណប្រសិនបើលោកយល់ព្រមសម្ភាសន៍ ដែលធ្វើឡើងដោយក្រុមរបស់យើងដើម្បីជ្រោមជ្រែងពួកយើងខ្ញុំក្នុងការស្រាវជ្រាវទៅលើការងារផ្នែកនេះ ។

យើងខ្ញុំចង់ដឹកនាំការសម្ភាសន៍ឱ្យបានឆាប់បើអាចធ្វើបាន និងមានគម្រោងប្រភេទសំណួររបស់យើងខ្ញុំខាងក្រោមដើម្បីជួយជ្រោមជ្រែងក្នុងការរៀបចំរបស់អ្នកឱ្យបានជាអតិបរិមា ។

- តើក្រុមហ៊ុនលោក.....(ឈ្មោះរបស់ក្រុមហ៊ុន) មានច្បាប់វិន័យដែលទាក់ទងទៅនឹងគោលនយោបាយនៃការទិញហើយសំណៅឯកសារថតចម្លងអាចត្រូវបានចែកចាយដែរឬទេ ?
- តើ(ឈ្មោះក្រុមហ៊ុន) ត្រួតពិនិត្យការអនុវត្តច្បាប់វិន័យនេះដោយរបៀបណា ?
- តើ (ឈ្មោះក្រុមហ៊ុន) គឺជាសមាជិកនៃការផ្តើមគំនិតតាំងពិពណិពាណិជ្ជកម្មដែរឬទេ ?
- តើ (ឈ្មោះក្រុមហ៊ុន) ប្រើប្រាស់ចំណេញសម្រាប់ផ្តើមគំនិតអភិវឌ្ឍពិភពលោកលើកទី ៣ ឬជួយគាំទ្រដល់ការបណ្តើមគំនិតនេះជាសាធារណៈឬទេ ?
- តើ (ឈ្មោះក្រុមហ៊ុន) មានទស្សនៈអ្វីខ្លះទៅលើពលកម្មកុមារ ? តើវាឆ្លុះបញ្ចាំងនូវតួនាទីរបស់ខ្លួននៅក្នុងចំនែកនៃទំនួលខុសត្រូវផ្នែកសង្គមយុទ្ធនាការជាអន្តរជាតិ ដើម្បីលុបបំបាត់ពលកម្មកុមារយ៉ាងដូចម្តេច ?

សូមអនុញ្ញាតឱ្យពួកយើងដឹងឱ្យបានឆាប់តាមលទ្ធភាពទៅសម្ភាសន៍នៅពេលណា ? អ្នកអាចទូរស័ព្ទប្រាប់ពួកយើងខ្ញុំឬសរសេរជាសំបុត្រមកកាន់ពួកយើងខ្ញុំដែលមានអាស័យដ្ឋានដូចខាងក្រោម (បញ្ចូលអាស័យដ្ឋាន និងលេខទូរស័ព្ទសម្រាប់ក្រុមដូចដែលបានប្រាប់ដូច្នេះហើយយើងអាចពិភាក្សាអំពីកាលបរិច្ឆេទ និងពេលវេលាសម្រាប់ក្រុមហ៊ុនរបស់លោកយ៉ាងសមរម្យ ។

សូមមេត្តាឆ្លើយតបឱ្យបានឆាប់ដែលអាចធ្វើទៅបាន ព្រោះថាពេលវេលាខ្លីសម្រាប់កុមារពលកម្មរាប់លាននាក់ទូទាំងសកលលោក ។

គណៈកម្មការជីកឆាំ និងគ្រប់គ្រង

១_លោក ភុង ហានស៊ីន	ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
២_លោក តូច ជឿន	អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៣_លោក គួច គូលំអ	អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៤_លោក ចាប គីមជុន	អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៥_លោក ណុប ទីម	ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

គណៈកម្មការរៀបរៀង និងចងក្រង

១_លោក ភុង ហានស៊ីន	ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
២_លោក តូច ជឿន	អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៣_លោក គួច គូលំអ	អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៤_លោក ចាប គីមជុន	អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៥_លោក ណុប ទីម	ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៦_លោក ឡង់ សុផាត	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

គណៈកម្មការបកប្រែ

១_លោកស្រី កង សុថាវី	ប្រធានការិយាល័យក្រោយអក្ខរកម្ម	២_លោកស្រី តុប ប៊ុនថា	ប្រធានការិយាល័យអក្ខរកម្ម
៣_លោក ព្ញ៉ែម ភីណារ៉ែត	អនុប្រធានការិយាល័យរដ្ឋបាល	៤_លោក តេះ ដារី	អនុប្រធានការ.ផែនការនិងគ្រប់គ្រងទិន្នន័យ
៥_លោក ជិន និវត្តន៍	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ	៦_លោកស្រី ទី វត្តី	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៧_លោក ភូ យន់	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ	៨_លោកស្រី ស្រ៊ុន ម៉ាទី	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៩_កញ្ញា អ៊ុក ធារី	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ	១០_លោក គ្រួច លក្ខិណា	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
១១_លោកស្រី លី ខេង	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ		

គណៈកម្មការផ្ទៀងផ្ទាត់

១_លោក សំ ចាន់ទិត	អនុប្រធានការិយាល័យអក្ខរកម្ម	២_លោក រង់ សូវង្ស	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៣_លោក ឈុំ ច័ន្ទមុនីរ៉ែត	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ	៤_លោកស្រី ជា សុផល	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៥_លោក កែវ គង់	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ	៦_កញ្ញា ម៉ៅ ផល្លី	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៧_លោកស្រី ស្រ៊ុន ម៉ាទី	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ		

គណៈកម្មការឌីហ្សាញ និងកុំព្យូទ័រ

១_លោក ឈិន វិត	ប្រធានការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន
២_លោក ពេជ្រ និពន្ធ	មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន
៣_លោកស្រី ឈុំ សោភ័ណ	មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន
៤_លោកស្រី សួច ផាន់ណា	មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន
៥_លោកស្រី ទី វ៉ាដា	មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន
៦_កញ្ញា សន សុម៉ាលី	មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន

✕ បញ្ឈប់ពលកម្មកុមារ

Stop Child Labour

Supporting Children's Rights through Education, the Arts and the Media (SCREAM)

សូមថ្លែងអំណរគុណ

- ដល់អង្គការពលកម្មអន្តរជាតិ (ILO) ដែលបានជួយឧបត្ថម្ភថវិកា ក្នុងការបកប្រែ រៀបរៀង និងបោះពុម្ព។
- ចំពោះលោក **មេឆណាធីរ៉ា ប៉ូល យូសេហ្វ** ប្រធានទីប្រឹក្សាបច្ចេកទេស និងលោក **ថេង ឆវីរិទ្ធ** មន្ត្រីកម្មវិធីនៃ *អង្គការពលកម្មអន្តរជាតិ* (ILO) កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC) គាំទ្រកម្មវិធីពេលវេលាកំណត់ (TBP SP) នៅកម្ពុជាដែលបានជួយផ្តល់ការណែនាំផ្សេងៗនិងការគាំទ្របច្ចេកទេស ព្រមទាំងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងនេះ ដើម្បី **ស្ក្រីម** (SCREAM) កើតមានឡើងនៅកម្ពុជា។

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមសេចក្តីប្រកាស
លេខ 101 អយក ប្រក ចុះថៃទី ២៣ ខែ មករា ឆ្នាំ ២០០៦

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ : លេខ ១៦៨ មហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកង១
ខណ្ឌ ចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទលេខ : ០២៣ ៧២៦ ៥៦៣ / ២១៩ ២៥៨

Email : nfe@camnet.com.kh

ISBN-9789995088217